01676385

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារ **D271/5 & D272/3**

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ៣៧ និង ៣៨)

**អង្គបុរេជំនុំជម្រះ**

ចំពោះមុខ៖ ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន៉ិយ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ៖ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១
ភាសាដើម៖ ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / 09 / 2021
ម៉ោង (Time/Heure): 10:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# សេចក្តីសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវីការពារក្តី មាស មុត ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០៣

**សហព្រះរាជអាជ្ញា៖**
ជា លាង
Brenda J. HOLLIS

**សហមេធាវីការពារក្តី មាស មុត ៖**
អាង ឧត្តម
Michael G. KARNAVAS

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
**និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គីមសួន
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ

Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

អង្គបុរេជំនុំជម្រះ
E.C.C.C. * C.E.T.C.
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

# មាតិកា


I. **ប្រវត្តិនីតិវិធី** ............................................................ ១

II. **ការបញ្ចូលនីតិវិធី** ............................................................ ៥

III. **សេចក្តីសង្ខេបមតិពាក់ព័ន្ធនឹងសេចក្តីសម្រេចថ្មីរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿង ០០៣** ............................................................ ៧

IV. **ភាពអាចទទួលយកបាន** ............................................................ ១០

ក. អំណះអំណាងរបស់ភាគីទាក់ទងនឹងសំណើរបស់សហមេធាវីការពារក្តី ............... ១០

១. សំណើរបស់សហមេធាវីការពារក្តី ............................................................ ១០

២. ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ............................................................ ១៥

ខ. ទឡ្ហីករណ៍របស់ភាគីចំពោះសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ................... ២០

១. សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ............................................................ ២០

២. ចម្លើយតបរបស់សហមេធាវីការពារក្តី ............................................................ ២៦

៣. ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ ............................................................ ៣៣

គ. ការពិនិត្យលើភាពអាចទទួលយកបាន ............................................................ ៣៤

១. តួនាទីរៀងៗខ្លួនរបស់ការិយាល័យចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ ... ៣៤

២. អង្គបុរេជំនុំជម្រះបានបំពេញភារកិច្ចរបស់ខ្លួនក្នុងសំណុំរឿង ០០៣ ................ ៣៩

V. **ផ្នែកសម្រេចសេចក្តី** ............................................................ ៤៤

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើរបស់ មាស មុត សុំបិទបញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ("សំណើរបស់មេធាវីការពារក្តី") ដែលបានដាក់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១[1] ព្រមទាំងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី នៅក្នុងសំណុំរឿង ០០៣ ("សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ") ដែលបានដាក់នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១[2] (រួមគ្នាហៅថា "សំណើ")។

## I. **ប្រវត្តិនីតិវិធី**

1. នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាបញ្ជូនខ្លួន មាស មុត ទៅជំនុំជម្រះ[3] រីឯសហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាលើកលែងការចោទប្រកាន់ មាស មុត (ជារួមហៅថា "ដីកាដំណោះស្រាយ")[4]។ ដីកាដំណោះស្រាយត្រូវបានចេញតែជាភាសាអង់គ្លេស និងជាភាសាខ្មែរ ដាច់ដោយឡែកពីគ្នា ហើយសំណៅបកប្រែត្រូវបានដាក់ជូនតាមក្រោយ។

---

[1] សំណុំរឿង ០០៣/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៣") សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ និងជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ និងជូនដំណឹងជាភាសាខ្មែរនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D272 ("សំណើរបស់សហមេធាវីការពារក្តី (D272)")។

[2] សំណុំរឿង០០៣ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D271/1 ("សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ D271/1)")។

[3] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D267)")។

[4] សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266 ("ដីកាសម្រេចលើកលែងចោទប្រកាន់ (D266)")។

2. នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាជាតិបានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[5] ជាភាសាខ្មែរ។ នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវីការពារក្ដី មាស មុត ("សហមេធាវីការពារក្ដី") (រួមគ្នាហៅថា "អ្នកដាក់ពាក្យសុំ") បានដាក់សារណាបណ្ដឹងឧទ្ធរណ៍រៀងៗខ្លួន ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់[6] និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[7] ជាភាសាអង់គ្លេស។

3. នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ("សេចក្ដីពិចារណាក្នុងសំណុំរឿង ០០៣")[8]។

4. នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិបានជូនដំណឹងអង្គបុរេជំនុំជម្រះ ពីបំណងក្នុងការដាក់សំណើសុំឱ្យអង្គជំនុំជម្រះបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០៣[9]។

---

[5] សំណុំរឿង ០០៣ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ ឯកសារ D267/3 ("បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D267/3)")។

[6] សំណុំរឿង ០០៣ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D266/2 ។

[7] សំណុំរឿង ០០៣ បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D267/4 ។

[8] សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ ឯកសារ D266/27 និង D267/35 ("សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35)")។

[9] សំណុំរឿង ០០៣ ការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីបំណងរបស់ខ្លួនក្នុងការដាក់សំណើសុំឲ្យអង្គបុរេជំនុំជម្រះបិទបញ្ចប់ដំណាក់កាលមុនជំនុំជម្រះ នៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ឯកសារ D271។

5. នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ សហមេធាវីការពារក្តីរបស់ មាស មុត ("សហមេធាវីការពារក្តី") បានដាក់ដាក់សំណើតែជាភាសាអង់គ្លេសប៉ុណ្ណោះ ដោយសុំឱ្យអង្គបុរេជំនុំជម្រះបិទបញ្ចប់ បោះត្រា និងតម្កល់សំណុំរឿង ០០៣ ក្នុងបណ្ណសារ[10]។

6. នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំឲ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ដោយផ្អែកលើការបញ្ជាក់រួមគ្នាពីអង្គបុរេជំនុំជម្រះ ថាត្រូវបញ្ជូន មាស មុត ទៅជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[11]។

7. នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ តាមរយៈសារអេឡិចត្រូនិក អង្គបុរេជំនុំជម្រះបានអញ្ជើញភាគីឱ្យដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើ៖ ១) ក្នុងចិរវេលា១០ថ្ងៃ បន្ទាប់ពីការជូនដំណឹងលើសំណើរបស់សហមេធាវីការពារក្តីជាភាសាខ្មែរ[12] និង ២) ក្នុងចិរវេលា១០ថ្ងៃ បន្ទាប់ពីការជូនដំណឹងស្តីពីការណែនាំរបស់អង្គជំនុំជម្រះ ទាក់ទងនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ("ការណែនាំ")[13]។

8. នៅថ្ងៃដដែលនោះ សហមេធាវីការពារក្តីបានដាក់សំណើសុំពន្យារពេលដាក់ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ("សំណើសុំពន្យារពេលរបស់មេធាវីការពារក្តី")[14]។

---

[10] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272)។

[11] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1)។

[12] សំណុំរឿង ០០៣ សារអេឡិចត្រូនិករបស់មន្ត្រីគ្រប់គ្រងសំណុំរឿងទាក់ទងនឹងការណែនាំភាគីរបស់អង្គបុរេជំនុំជម្រះ (ទាក់ទងនឹង អបជ ៣៨) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១។

[13] សំណុំរឿង ០០៣ សារអេឡិចត្រូនិករបស់មន្ត្រីគ្រប់គ្រងសំណុំរឿងទាក់ទងនឹងការណែនាំភាគីរបស់អង្គបុរេជំនុំជម្រះ (ទាក់ទងនឹង អបជ ៣៨) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១។

[14] សំណុំរឿង ០០៣ សំណើរបស់ មាស មុត សុំពន្យារពេលចម្លើយរបស់ខ្លួន តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D271/2។

9. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិបានជូនដំណឹងថា លោកស្រីមិនមានបំណងប្រកាន់ជំហរណាមួយឡើយចំពោះសំណើសុំពន្យារពេលរបស់សហមេធាវីការពារក្តី ហើយទុកឱ្យអង្គបុរេជំនុំជម្រះជាអ្នកវាយតម្លៃ[15]។

10. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះបានសម្រេចលើសំណើសុំពន្យារពេលដាក់ចម្លើយតបរបស់សហមេធាវីការពារក្តី ដោយផ្តល់ថិរវេលា៥ថ្ងៃបន្ថែមសម្រាប់ដាក់ចម្លើយតប[16]។

11. នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើរបស់សហមេធាវីការពារក្តី ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ") ជាភាសាអង់គ្លេសតែប៉ុណ្ណោះ រីឯសំណៅបកប្រែជាភាសាខ្មែរត្រូវដាក់ជូនតាមក្រោយ[17]។

12. នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ ក្រុមមេធាវីការពារក្តីបានដាក់ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ("ចម្លើយតបរបស់សហមេធាវីការពារក្តី") ជាភាសាអង់គ្លេសតែប៉ុណ្ណោះ រីឯសំណៅបកប្រែជាភាសាខ្មែរនឹងត្រូវដាក់ជូនតាមក្រោយ[18]។ នៅថ្ងៃដដែល សហព្រះរាជអាជ្ញាជាតិបាន

---

[15] សំណុំរឿង ០០៣ សារអេឡិចត្រូនិករបស់សហព្រះរាជអាជ្ញារងអន្តរជាតិផ្ញើជូនលោកចៅក្រមអង្គបុរេជំនុំជម្រះទាក់ទងនឹងសំណើសុំពន្យារពេលរបស់ក្រុមមេធាវីការពារក្តី (ឯកសារ D271/2) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១។

[16] សំណុំរឿង ០០៣ សារអេឡិចត្រូនិករបស់ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះផ្ញើជូនមេធាវីនៃសហមេធាវីការពារក្តី ទាក់ទងនឹងសំណើរបស់ មាស មុត សុំពន្យារពេលរបស់ក្រុមមេធាវីការពារក្តី (ឯកសារ D271/2) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១។

[17] សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ មាស មុត សុំឱ្យបញ្ចប់នីតិវិធី បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ចុះនិងដាក់នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១ ជាភាសាអង់គ្លេស ឯកសារ D272/1 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D272/1)")។

[18] សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ មាស មុត សុំឱ្យបញ្ចប់នីតិវិធី បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ចុះនិងដាក់នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ ជាភាសាអង់គ្លេស ឯកសារ D271/3 ("ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3)")។

ដាក់ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ")[19]។

13. នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះបានច្រានចោល[20] សំណើរបស់ក្រុមមេធាវីការពារក្តី ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ដែលបានសុំការអនុញ្ញាតឆ្លើយតបទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[21]។

## II. ការបញ្ចូលនីតិវិធី

14. ដូចបានបញ្ជាក់ជូនខាងលើ[22] អង្គបុរេជំនុំជម្រះបានទទួលសំណើពីរ មួយពីសហមេធាវីការពារក្តី និងមួយទៀតពីសហព្រះរាជអាជ្ញាអន្តរជាតិ។

15. អនុលោមតាមមាត្រា ១២.១ នៃកិច្ចព្រមព្រៀង អ.វ.ត.ក[23] និងវិធាន ២ នៃវិធានផ្ទៃក្នុង[24] ប្រសិនបើមានបញ្ហាណាមួយកើតមានឡើង ដែលមិនមានចែងក្នុងអត្ថបទច្បាប់ អ.វ.ត.ក អង្គជំនុំជម្រះត្រូវធ្វើ

---

[19] សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹង សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ចុះនិងដាក់នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ ជាភាសាអង់គ្លេសនិងភាសាខ្មែរ ឯកសារ D271/4 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D272/1)")។

[20] សំណុំរឿង ០០៣ សារអេឡិចត្រូនិករបស់អ្នកគ្រប់គ្រងសំណុំរឿងទៅកាន់ភាគី ដោយជូនដំណឹងអំពីសេចក្តីសម្រេចនៃអង្គបុរេជំនុំជម្រះទាក់ទងនឹងសំណើសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១។

[21] សំណុំរឿង ០០៣ សំណើសុំធ្វើការឆ្លើយតបទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិតបទៅនឹងសំណើរបស់ មាស មុត សុំឲ្យបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ឯកសារ D272/2។

[22] សូមមើលខាងលើ ទំព័រ១ កថាខណ្ឌ ៥ និង ៦។

[23] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះហត្ថលេខានៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ១២.១។

ការសម្រេចដោយអនុលោមទៅតាមច្បាប់កម្ពុជា។ ត្រង់ចំណុចនេះ អង្គបុរេជំនុំជម្រះរំឭក[25] ថា មាត្រា ២៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានចែងថា "កាលណាតុលាការទទួលបាននីតិវិធីច្រើន ដែលមានអង្គហេតុច្រើនជាប់ទាក់ទងគ្នា តុលាការអាចបង្គាប់ឱ្យបញ្ចូលនីតិវិធីទាំងនោះជាមួយគ្នាបាន"[26]។

16. ក្នុងករណីនេះ អង្គបុរេជំនុំជម្រះបានទទួលនីតិវិធីពីរបែប ដែលមានទម្រង់ជាសំណើពីរច្បាប់ ដែលបានដាក់ បន្ទាប់ពីបានចេញសេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ ដោយបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿងនេះ ១) តាមរយៈការប្រកាសបិទបញ្ចប់នីតិវិធី បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ (សំណើរបស់សហមេធាវីការពារក្តី) ឬ ២) តាមរយៈការបញ្ជូន មាស មុត ទៅជំនុំជម្រះចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ)។ ដោយសំណើទាំងពីរនេះអនុវត្តតាមនីតិវិធីបណ្តឹងឧទ្ធរណ៍ដូចគ្នា ហើយពាក់ព័ន្ធនឹងអង្គហេតុនិងជនជាប់ចោទម្នាក់ដូចគ្នា អង្គបុរេជំនុំជម្រះយល់ឃើញថា ក្នុងករណីនេះ នីតិវិធីទាំងនេះមានភាពជាប់ពាក់ព័ន្ធគ្នា។

17. ផ្អែកលើសិទ្ធិអំណាចក្នុងការបង្គាប់ឲ្យបញ្ចូលគ្នានូវកិច្ចដំណើរការនីតិវិធីច្រើនជាប់ទាក់ទងគ្នា កាតព្វកិច្ចក្នុងការធានាឱ្យមានដំណើរការស្វែងរកយុត្តិធម៌ឱ្យបានត្រឹមត្រូវនិងឆាប់រហ័ស ក៏ដូចជាភាពចាំបាច់ក្នុងការបញ្ចៀសដំណោះស្រាយដែលមិនអាចសម្រុះសម្រួលគ្នាបាន ក្នុងករណីដែលរឿងក្តីត្រូវវិនិច្ឆ័យដាច់ពីគ្នា អង្គបុរេជំនុំជម្រះយល់ឃើញថា ការបញ្ចូលនីតិវិធី គឺពិតជាសមហេតុផល។

---

[24] *វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* (វិសោធលើកទី ៩) ត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី១៦ ខែមករា ឆ្នាំ ២០១៥ ("វិធានផ្ទៃក្នុង")។

[25] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) កថាខណ្ឌ៣៨។ សំណុំរឿង ០០៤/២/០៧-០៩-២០០៩ អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤/២") (អបជ ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និង D360/33 ("សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ("ឯកសារ D359/24 និង D360/33)") កថាខណ្ឌ ២៥។

[26] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧) ("ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា") មាត្រា ២៩៩។

18. អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះបង្គាប់ឱ្យដាក់បញ្ចូលនីតិវិធី ហើយនឹងពិនិត្យរួមគ្នានូវសំណើទាំងឡាយ នៅក្នុងសេចក្តីសម្រេចនេះ។

## III. សេចក្តីសង្កេតបឋមពាក់ព័ន្ធនឹងសេចក្តីសម្រេចថ្មីរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿង ០០៣

19. អង្គបុរេជំនុំជម្រះសង្កេតដោយងឿងឆ្ងល់ នូវការបកស្រាយដ៏វែងអន្លាយរបស់សហចៅក្រមស៊ើបអង្កេត ទៅលើការវាយតម្លៃលើដំណើរការស៊ើបអង្កេតតាមផ្លូវតុលាការ នៅពេលអនុវត្តយុត្តាធិការបណ្តឹងឧទ្ធរណ៍របស់ខ្លួន[27]។ អង្គជំនុំជម្រះកត់សម្គាល់ថា នៅពេលនេះ វាយឺតពេលហើយដែលសហចៅក្រមស៊ើបអង្កេតវិលទៅប្រកាន់យកការអនុវត្តមួយសមរម្យនិងស្របច្បាប់ ដែលសហចៅក្រមបានដកចេញម្តងហើយម្តងទៀត ដើម្បីជាប្រយោជន៍ដល់អ្វីដែលពួកគាត់ហៅថាការអនុវត្តតាម "ឆន្ទានុសិទ្ធិ" របស់ខ្លួន[28]។ សេចក្តីសម្រេចថ្មីរបស់សហចៅក្រមស៊ើបអង្កេត ហាក់ដូចជាមិនដើរឆ្ពោះទៅតាមទិសដៅនេះឡើយ។ ជាក់ស្តែង ផ្ទុយពីការអះអាងរបស់ខ្លួន អង្គបុរេជំនុំជម្រះមិនបាន "ពង្រីកទំហំនៃករណីយកិច្ចក្នុងការដាក់ការខ្វែងយោបល់គ្នារបស់ចៅក្រមស៊ើបអង្កេត ទៅកាន់អង្គបុរេជំនុំជម្រះសម្រាប់ស្វែងរកដំណោះស្រាយ" នោះឡើយ[29]។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះប្រកាន់យក

---

[27] សូមមើល សំណុំរឿង ០០៣ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ឯកសារ D270/7 ("សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង" (ឯកសារ D270/7) កថាខណ្ឌ ៨ ដល់ ២៧។

[28] សូមមើលឧទាហរណ៍ ដីកាដំណោះស្រាយ (ឯកសារ D267) កថាខណ្ឌ ១៩ ដែលយោងទៅសំណុំរឿង ០០៣ ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D262.2 ("ដីកាសម្រេចលើសំណើដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (ឯកសារ D262.2)") កថាខណ្ឌ ១៣ ដល់ ១៦។ ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (ឯកសារ D266) កថាខណ្ឌ ៧ ដែលយោងទៅ ដីកាសម្រេចលើសំណើដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (ឯកសារ D262.2) កថាខណ្ឌ ១៥ (តាមរយៈអំណានរួមគ្នាលើដីកាសម្រេចនោះ សហចៅក្រមស៊ើបអង្កេតបានវាយតម្លៃដោយខុសឆ្គងថា បុព្វសិទ្ធិរបស់ខ្លួនក្នុងការប្តឹងអង្គបុរេជំនុំជម្រះស្តីពីការខ្វែងគំនិត គឺជាឆន្ទានុសិទ្ធិ ហើយមិនមែនជាកាតព្វកិច្ចទេ)។

[29] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង (ឯកសារ D270/7) កថាខណ្ឌ ១៥។

ការអនុវត្តច្បាប់យ៉ាងតឹងរ៉ឹង និងបដិសេធទង្វើតាមទំនើងចិត្ត។ លើសពីនេះទៀត នៅក្នុងសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះរកឃើញការប៉ុនប៉ងផ្ដល់យុត្តិកម្ម និងការលើកឡើងស្មានៗមិនត្រឹមត្រូវ[30] ដោយមិនពាក់ព័ន្ធនឹងសំណើបញ្ជូនទៅសហចៅក្រមស៊ើបអង្កេតឡើយ។

20. ទោះបីសហចៅក្រមស៊ើបអង្កេតមិនពេញចិត្តចំពោះការវាយតម្លៃរបស់អង្គបុរេជំនុំជម្រះ លើកិច្ចព្រមព្រៀងបិទបញ្ចប់ការស៊ើបអង្កេតតាមផ្លូវតុលាការ តាមរយៈការចេញដីកាផ្ទុយគ្នា តែអង្គបុរេជំនុំជម្រះបានបំពេញភារកិច្ចរបស់ខ្លួនក្នុងការត្រួតពិនិត្យលើចៅក្រមដំបូងៗតាម ការអនុវត្តច្បាប់យ៉ាងតឹងរ៉ឹងរបស់ខ្លួន[31]។ អង្គបុរេជំនុំជម្រះបានរំលឹកជាច្រើនលើកច្រើនសាថា "ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតក្នុងការកំណត់[លើយុត្តាធិការបុគ្គល]នេះ គឺជាអំណាចតុលាការដែលមិនអនុញ្ញាតឲ្យបំពេញកិច្ចតាមទំនើងចិត្ត និងដែលត្រូវអនុវត្តទៅតាមគោលការណ៍ច្បាប់ដែលបានអនុម័ត"[32]។

---

[30] សូមមើល សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង (ឯកសារ D270/7) កថាខណ្ឌ ១៣ ដល់ ២៥ (ដែលនៅក្នុងការវិភាគសង្ខេបខ្លីៗនោះ មានប្រើប្រាស់ស្ថានភាពមានលក្ខខណ្ឌជាច្រើនសន្និកសន្ទាប់ [សម្រាប់ពណ៌នាពីសកម្មភាពមិនជាក់លាក់] និងមានប្រើឈ្នាប់ "ប្រសិនបើ" ដែលជាសន្ទានសព្ទបញ្ជាក់ពីការសន្មតដោយការប៉ាន់ស្មាន និងពាក្យពេចន៍មួយចំនួនធំដូចជា "យើងខ្ញុំមិនយល់ទេ" "មិនមានហេតុផលអ្វីទៅជឿជាក់លើ" "បែបអច្ឆរិយៈ" "ទាំងនោះអាចនឹងបង្ករឱ្យមាន" "យើងមិនដឹង" "មិនអាចថាមិនអាចប្រមើលទុកមុនបានឡើយ" "យើងសង្ស័យថា"។ល។)។

[31] សូមមើល សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៤៣ ដល់ ៤៨។ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ១២១ ដល់ ១៣០។

[32] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៤៩។ សូមមើលផងដែរ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) កថាខណ្ឌ ៤៥។ សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤/១") (អបជ ៥០) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 ("សំណុំរឿង ០០៤/១ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20)") កថាខណ្ឌ ២០។

21. នៅក្នុងបរិបទនេះ អង្គបុរេជំនុំជម្រះតែងតែប្រុងប្រយ័ត្នខ្ពស់បំផុត ក្នុងការអនុវត្តយុត្តាធិការរបស់ខ្លួនក្នុងដំណាក់កាលស៊ើបអង្កេត[33] ហើយភាពម៉ឺងម៉ាត់នៃការវាយតម្លៃរបស់អង្គបុរេជំនុំជម្រះចំពោះវិវាទនៃដីកាដំណោះស្រាយដែលមិនធ្លាប់មានពីមុនមក ត្រូវបានបង្ហាញតាមរយៈការអនុវត្តមិនសមស្របដោយចេតនានូវមុខងារយុត្តិធម៌ ដែលត្រូវបានប្រគល់ជូនសហចៅក្រមស៊ើបអង្កេត[34] ទោះបីជាមានការព្រមានជាច្រើនពីអង្គជំនុំជម្រះយ៉ាងណាក៏ដោយ[35]។

22. អង្គបុរេជំនុំជម្រះសោកស្តាយជាខ្លាំង ចំពោះការដែលចៅក្រមទាំងនេះមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ហើយបែរជាចាត់ទុកខ្លួនឯងថាជាជនរងគ្រោះទៅវិញ[36] នៅពេលកំហុសធ្ងន់ធ្ងររបស់ខ្លួនត្រូវបានលាតត្រដាង។ ទោះបីចៅក្រមទាំងនេះបានដឹងច្បាស់ថាខ្លួនបានរំលោភបំពានច្បាប់ជាធរមានក៏ដោយ តែពួកគេបែរជាបណ្តោយឱ្យខូចខាតដល់ប្រព័ន្ធតុលាការទាំងមូល ហើយរុញច្រានភាគីទាំងអស់ឲ្យធ្លាក់ចូលទៅក្នុងភាពមិនច្បាស់លាស់ផ្នែកគតិយុត្ត រួមទាំងអ្នកដាក់ពាក្យសុំ និងជនរងគ្រោះរាប់ម៉ឺននាក់នៃឧក្រិដ្ឋកម្ម ដែលពួកគេទទួលខុសត្រូវផ្ទាល់ក្នុងការស៊ើបអង្កេត។

23. អង្គបុរេជំនុំជម្រះសូមសម្តែងជាថ្មីនូវចេតនាដ៏មុតមាំ ក្នុងការបំពេញមុខងាររបស់ខ្លួនដោយឥតលម្អៀង និងស្របតាមផ្លូវច្បាប់រហូតដល់ចប់ចុងចប់ដើម។ អង្គជំនុំជម្រះសូមកត់សំគាល់ផងដែរថា កំហុស

---

[33] សូមមើលសំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៥៣។

[34] សូមមើលសំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៣៥ និង ៣៦។

[35] ឧទាហរណ៍ សូមមើល សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ២៨ ដល់ ៣១, ៣២ ដល់ ៣៥ និង ៥២ ដល់ ៥៦។ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៦០ ដល់ ៧២ និង ៧៣ ដល់ ៨៣។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ១៣១ ដល់ ១៣៤ និង ១៣៥ ដល់ ១៤៩។

[36] សូមមើល សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង (ឯកសារ D270/7) កថាខណ្ឌ ១០ ដល់ ១៣។

របស់សហចៅក្រមស៊ើបអង្កេត ដែលធ្វើឱ្យប៉ះពាល់រហូតដល់គ្រឹះនៃប្រព័ន្ធតុលាការកូនកាត់ អ.វ.ត.ក និងដល់ដំណើរការរបស់តុលាការ[37] ទាមទារឱ្យមានអន្តរាគមន៍ពីអង្គជំនុំជម្រះទៅលើករណីនេះ។

## IV. ភាពអាចទទួលយកបាន

### ក. អំណះអំណាងរបស់ភាគីទាក់ទងនឹងសំណើរបស់សហមេធាវីការពារក្តី

### ១. សំណើរបស់សហមេធាវីការពារក្តី

24. នៅក្នុងសំណើរបស់ខ្លួន ជាបឋម សហមេធាវីការពារក្តីបានលើកឡើងយ៉ាងលម្អិតពីហេតុផលក្នុងការទទួលយកសំណើ[38]។ មេធាវីបង្ហាញជាអាទិ៍ថា អង្គបុរេជំនុំជម្រះមានភារកិច្ចសម្រេចលើបញ្ហាទាំងឡាយដែលលើកឡើងនៅក្នុងសំណើ ពីព្រោះអង្គជំនុំជម្រះមានសមត្ថកិច្ចចុងក្រោយបង្អស់ នៅក្នុងដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី ដែលអង្គជំនុំជម្រះត្រូវតែអនុវត្ត ទោះក្នុងករណីដែលច្បាប់នោះមិនមានចែង ចែងមិនច្បាស់ ឬមិនគ្រប់គ្រាន់ក៏ដោយ[39]។ សហមេធាវីការពារក្តីបន្ថែមថា ដោយអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះមានកាតព្វកិច្ចធ្វើការបកស្រាយនៅក្នុងក្របខណ្ឌច្បាប់ សំដៅការពារប្រយោជន៍របស់ជនត្រូវចោទ និងមានកាតព្វកិច្ចអនុវត្តយុត្តាធិការដែលមានស្រាប់ ក្នុងការធានានូវការគ្រប់គ្រងតុលាការឲ្យបានល្អនិងត្រឹមត្រូវ[40]។ ទីបញ្ចប់ សហមេធាវីការពារក្តីអះអាងថា សំណើរបស់ខ្លួនទាក់ទងទៅនឹងបញ្ហាដ៏មានសារៈសំខាន់ជាទូទៅ

[37] សូមមើល សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និងD267/35) កថាខណ្ឌ ១០៦។ សូមមើលផងដែរ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៥៤ ("ដែលជាការរំលោភបំពានទាំងស្រុងលើមូលដ្ឋាននៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក តែម្តង")។

[38] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៤៦។

[39] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៤៦។

[40] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៤៦។

សម្រាប់យុត្តិសាស្ត្រ និងកេរដំណែលរបស់ អ.វ.ត.ក ហើយថា ការសម្រេចលើបញ្ហាទាំងនេះនឹងផ្តល់ការបំភ្លឺពីនីតិវិធី និងជួយសន្សំសំចៃធនធានរបស់តុលាការ[41]។

25. ពាក់ព័ន្ធនឹងអង្គសេចក្តី សហមេធាវីការពារក្តីអះអាងថា ក្នុងករណីដែលមិនអាចបញ្ជូន មាស មុត ទៅជំនុំជម្រះក្តីដោយសំឡេងភាគច្រើន អង្គបុរេជំនុំជម្រះមានកាតព្វកិច្ចផ្លូវច្បាប់ក្នុងការបិទបញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៣ ក្នុងបណ្ណសារ[42] ពីព្រោះថា ១) មាស មុត មានសិទ្ធិទទួលបានដំណើរការនីតិវិធីឆាប់រហ័ស[43] ២) ភាពយឺតយ៉ាវនៅក្នុងកិច្ចដំណើរការនីតិវិធីដ៏យូរអស់រយៈពេល១៣ឆ្នាំ គឺមិនសមហេតុផលទេ[44] និង ៣) ដំណើរការនីតិវិធីជំនុំជម្រះនិងបណ្តឹងឧទ្ធរណ៍ស៊ីពេលយ៉ាងតិចបួនឆ្នាំ ដើម្បីឈានទៅដល់លទ្ធផលលើកលែងការចោទប្រកាន់ដែលជៀសមិនរួច[45]។ ដូច្នេះ ៤) អង្គបុរេជំនុំជម្រះត្រូវតែបិទបញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ក្នុងករណីអង្គបុរេជំនុំជម្រះមិនអាចទទួលបានសំឡេងភាគច្រើនលើសលប់ដើម្បីបញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះ[46]។

26. ទីមួយ សហមេធាវីការពារក្តីនៅតែអះអាងថា ចិរវេលាធម្មតាសម្រាប់រៀបចំដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី នៅក្នុងសំណុំរឿង ០០៣ មិនត្រូវបានគោរពឡើយ[47] ដោយរំឭកថា វិធាន ២១.៤ នៃវិធានផ្ទៃក្នុង តម្រូវឱ្យដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ត្រូវបញ្ចប់ក្នុងរយៈពេលមួយសមស្រប[48]។ សហមេធាវីការពារក្តីអះអាងថា សិទ្ធិទទួលបានដំណើរការនីតិវិធីឆាប់រហ័ស

---

[41] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៤៦។

[42] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៤៧។

[43] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៤៨ ដល់ ៥០។

[44] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៥១ ដល់ ៥៥។

[45] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៥៦ ដល់ ៥៩។

[46] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៦០ ដល់ ៦៩។

[47] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ១, ៣៤, ៤៧ ដល់ ៥៥ និង ៦៥។

[48] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៤៨។

01676398



ក្នុងវិធាន ២១.៤ ស្របគ្នានឹងមាត្រា ៣៥ *ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[49] គឺជាគោលការណ៍គ្រឹះ ដូចមានចែងក្នុងមាត្រា ១៤.(៣)(គ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និង ក្នុងមាត្រា ៣១ និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា ក៏ដូចជានៅក្នុងអនុសញ្ញាស្តីពីសិទ្ធិមនុស្សរបស់ អឺរ៉ុប អាហ្វ្រិក និងអាមេរិក[50]។

27. ទីពីរ សហមេធាវីការពារក្តីអះអាងថា ការខ្វែងមតិគ្នារវាងភាគីជាតិ និងអន្តរជាតិ នៃអ.វ.ត.ក[51] បាន បង្កការយឺតយ៉ាវហួសហេតុនិងដែលអាចចៀសវាងបាន នៅក្នុងដំណើរការនីតិវិធីមុនការជំនុំជម្រះក្តី ០០៣ ដែលអូសបន្លាយមកដល់ពេលនេះអស់រយៈពេល ១៣ ឆ្នាំ[52] និងដែលមិនគោរពតាម គោលការណ៍ជំនុំជម្រះក្តីក្នុងចិរវេលាសមស្របសោះឡើយ។ សហមេធាវីការពារក្តីបានវែកញែកពីការ មិនចុះសម្រុងគ្នា ថាតើគួរបញ្ជូន មាស មុត ទៅជំនុំជម្រះឬអត់។ បន្ទាប់មក សហមេធាវីការពារក្តី ក៏ បានរំឭកអំពីហេតុផលនៃការយឺតយ៉ាវខាងលើនេះ និងជាពិសេស ពីការខ្វែងយោបល់គ្នារវាងសហ ព្រះរាជអាជ្ញាក្នុងការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យទៅស៊ើបសួរ[53] ការខ្វែងយោបល់គ្នារវាងសហ ចៅក្រមស៊ើបអង្កេត[54] និងរវាងចៅក្រមនៃអង្គបុរេជំនុំជម្រះ ទាក់ទងនឹងថាតើគួរបញ្ជូន ឬមិនបញ្ជូន មាស មុត ទៅជំនុំជម្រះ[55]។

28. លើសពីនោះទៀត សហមេធាវីការពារក្តីអះអាងថា ភាពស្មុគស្មាញនៃសំណុំរឿងនេះ ដែលពាក់ព័ន្ធតែ ជនត្រូវចោទម្នាក់ ទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ចំនួនប្រាំបីកន្លែង និងតួនាទីកងទ័ពបដិវត្តន៍កម្ពុជា

---

[49] *ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ* ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ នស/រកម/១០០៤/០០៦ ត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០០៤ (“ច្បាប់ស្តីពី អ.វ.ត.ក”)។

[50] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៤៨។

[51] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៥១ ដល់ ៦៩។

[52] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៥១ ដល់ ៦៥។

[53] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៥១.ក។

[54] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៥១.ខ។

[55] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៥១.គ និង ឃ។

របស់គាត់ មិនអាចយកមកពន្យល់ ហើយក៏មិនអាចយកជាហេតុផលចំពោះនីតិវិធីស៊ើបសួររយៈពេល ១៣ ឆ្នាំ ដែលមានរយៈពេលបីដងយូរជាងដំណើរការនីតិវិធីជម្រះក្ដីក្នុងសំណុំរឿង ០០២[56]។ ដូចគ្នាដែរ ទង្វើរបស់ មាស មុត មិនមែនជាដើមចមនៃការពន្យារពេលដំណើរការនីតិវិធីឡើយ ព្រោះថា គាត់បានអនុវត្តទាំងស្រុងតាមលក្ខខណ្ឌបង្គាប់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចៅក្រម Bohlander[57]។ សហមេធាវីការពារក្ដីបានបញ្ជាក់ផងដែរថា ការចោទប្រកាន់លើ មាស មុត អាយុ៨២ឆ្នាំ ដោយសហចៅក្រមស៊ើបអង្កេតម្នាក់ នឹងធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់គាត់និងគ្រួសារជារៀងរហូត ហើយលទ្ធភាពនៃការជំនុំជម្រះក្ដីដោយយុត្តិធម៌ កំពុងថយចុះជាលំដាប់ ទៅតាមពេលវេលា[58]។

29. ទីបី សហមេធាវីការពារក្ដីយល់ឃើញថា ឧបមាថាអង្គបុរេជំនុំជម្រះយល់ព្រមដោយមានសម្លេងភាគច្រើនគ្រប់គ្រាន់ ក្នុងការបញ្ជូនរឿងក្ដី មាស មុត ទៅជំនុំជម្រះ ការជំនុំជម្រះសេចក្ដីនឹងមិនអាចចាប់ផ្ដើមមុនខែឧសភា ឆ្នាំ២០២២ ឡើយ[59]។ សហមេធាវីការពារក្ដីអះអាងថា អង្គជំនុំជម្រះសាលាដំបូងដែលអាចខ្វែងយោបល់គ្នា នៅពេលពិនិត្យលើអញ្ញត្រកម្មទាក់ទងនឹងយុត្តាធិការរបស់ អ.វ.ត.ក លើ មាស មុត នឹងចេញសាលក្រមលើកលែងការចោទប្រកាន់ ហើយសាលក្រមនោះទំនងជានឹងត្រូវបានតម្កល់ដោយអង្គជំនុំជម្រះតុលាការកំពូល[60]។ សហមេធាវីការពារក្ដីបន្តបទបង្ហាញរបស់ខ្លួន ដោយទាញការលើកឡើងស្មានៗថា ប្រសិនបើ មាស មុត ត្រូវបានលើកលែងការចោទប្រកាន់ (ពួកគាត់យល់ឃើញថាវាជាការសន្មតសមហេតុផល ដោយផ្អែកទៅការលើកឡើងនៅក្នុងសំណុំរឿង ០០៤/២ របស់ចៅក្រមជាតិនៃអង្គជំនុំជម្រះសាលាដំបូង ដែលថាសំណុំរឿងនេះនឹងត្រូវបិទបញ្ចប់ដោយអង្គបុរេជំនុំជម្រះ)[61] សហព្រះរាជអាជ្ញាអន្តរជាតិនឹងប្ដឹងសាទុក្ខប្រឆាំងនឹងការលើក

---

[56] សំណើរបស់សហមេធាវីការពារក្ដី (ឯកសារ D272) កថាខណ្ឌ ៥២។

[57] សំណើរបស់សហមេធាវីការពារក្ដី (ឯកសារ D272) កថាខណ្ឌ ៥៣។

[58] សំណើរបស់សហមេធាវីការពារក្ដី (ឯកសារ D272) កថាខណ្ឌ ៥៤ និង ៥៥។

[59] សំណើរបស់សហមេធាវីការពារក្ដី (ឯកសារ D272) កថាខណ្ឌ ៥៦ និង ៥៧។

[60] សំណើរបស់សហមេធាវីការពារក្ដី (ឯកសារ D272) កថាខណ្ឌ ៥៦។

[61] សំណើរបស់សហមេធាវីការពារក្ដី (ឯកសារ D272) កថាខណ្ឌ ៥៩។

លែងការចោទប្រកាន់ជាយថាហេតុ ដោយអង្គជំនុំជម្រះសាលាដំបូង។ ប្រការនេះនាំឱ្យសហមេធាវីប៉ាន់ប្រមាណថា ទាល់តែដល់ឆ្នាំ២០២៦ ទើបអង្គជំនុំជម្រះតុលាការកំពូល អាចចេញសាលដីកាបាន[62]។

30. នៅក្នុងទឡ្ហីករណ៍ទីបួនរបស់ខ្លួន សហមេធាវីការពារក្តីអះអាងថា អង្គបុរេជំនុំជម្រះដែលមានកាតព្វកិច្ចធានាឱ្យមានការគោរពគោលការណ៍ជាមូលដ្ឋាននៃនីតិវិធីចំពោះមុខ អ.វ.ត.ក ក្នុងដំណាក់កាលស៊ើបអង្កេត ត្រូវតែបិទបញ្ចប់នីតិវិធីក្នុងសំណុំរឿង ០០៣ បោះត្រា និងតម្កល់ទុកក្នុងបណ្ណសារដើម្បីធានានិយតភាព នៃនីតិវិធី ប្រសិនបើអង្គបុរេមិនអាចចេញសេចក្តីសម្រេចមានសម្លេងគាំទ្រជាឯកច្ឆ័ន្ទ ឬមានសម្លេងគាំទ្រគ្រប់គ្រាន់ ទាក់ទងនឹងដំណោះស្រាយលើដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី[63]។ សហមេធាវីការពារក្តីអះអាងថា គោលការណ៍រំលោភបំពាននីតិវិធីត្រូវបានរកឃើញថាពិតជាមាននៅកម្រិតអន្តរជាតិ និងនៅក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក តាមលក្ខណៈបង្កប់ន័យ ហើយគោលការណ៍នេះត្រូវបានគ្រោងទុកជាមុនដោយសហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះតុលាការកំពូល និងដោយច្បាប់កម្ពុជា[64]។ សហមេធាវីការពារក្តីបន្តអះអាងថា គោលការណ៍នេះអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះប្រើប្រាស់ឆន្ទានុសិទ្ធិ ដើម្បីបដិសេធការអនុវត្តយុត្តាធិការរបស់ខ្លួន ក្នុងករណីមានការរំលោភបំពានធ្ងន់ធ្ងរជាក់ស្តែងលើសិទ្ធិជនជាប់ចោទ និងការអនុវត្តយុត្តាធិការអាចធ្វើឱ្យប៉ះពាល់ដល់សុចរិតភាពរបស់តុលាការ[65]។ សហមេធាវីការពារក្តីលើកឡើងថា ដោយពុំមានពន្លឺណាមួយថានឹងអាចចេញសាលក្រម ក្នុងរយៈពេលមួយសមរម្យ ឬអាចផ្តន្ទាទោសមាស មុត[66] នៅទីបញ្ចប់នៃការកាត់សេចក្តី អង្គបុរេជំនុំជម្រះធ្វើឱ្យខ្លួនជាប់ពិរុទ្ធ ដោយសារ

---

[62] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៥៦ និង៥៩។

[63] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៦០ និង ៦១។

[64] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៦២ ដល់ ៦៤។

[65] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៦៣។

[66] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៦២។

វិលោភកិច្ចដំណើរការនីតិវិធី ប្រសិនបើខ្លួនមិនបញ្ចប់ភ្លាមៗនូវនីតិវិធីប្រឆាំងនឹង មាស មុត ឬ សម្រេចបញ្ជូន មាស មុត ទៅជំនុំជម្រះ[67]។

31. ជាបញ្ចប់ សហមេធាវីការពារក្តីបានចោទថា មាស មុត ត្រូវបានដកហូតសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហើយអង្គបុរេជំនុំជម្រះមានកាតព្វកិច្ចការពារសិទ្ធិការពារក្តី និងរក្សាសុចរិតភាពរបស់ អ.វ.ត.ក[68]។ សហមេធាវីការពារក្តីអះអាងថា អង្គជំនុំជម្រះមានមធ្យោបាយផ្សេងៗដើម្បីចេញឱ្យផុតពីភាពមិនច្បាស់លាស់របស់តុលាការនាពេលបច្ចុប្បន្ន ឧទាហរណ៍ដូចជាស៊ើបអង្កេតលើសំណុំរឿងនេះ ដោយខ្លួនឯង និងចេញដីកាដំណោះស្រាយដោយខ្លួនឯង[69]។ សហមេធាវីការពារក្តីរម្លឹកឡើងវិញថា ប្រសិនបើអង្គបុរេមិនអាចចេញសេចក្តីសម្រេចជាស្ថាពរដែលមានអានុភាពចាប់បង្ខំ និងបិទបញ្ចប់កិច្ចដំណើរការនីតិវិធីស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ដោយមានសម្លេងគាំទ្រជាឯកច្ឆន្ទ ឬដោយសម្លេងភាគច្រើនគ្រប់គ្រាន់ទេ អង្គជំនុំជម្រះមានកាតព្វកិច្ចអនុវត្តយុត្តាធិការនិងច្បាប់ជាធរមាន ដើម្បីបិទបញ្ចប់នីតិវិធីនៅក្នុងសំណុំរឿង ០០៣ និងបន្ទាប់មក បោះត្រានិងតម្កល់ទុកក្នុងបណ្ណសារ[70]។

## ២. ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

32. ក្នុងចម្លើយតបទៅនឹងសំណើរបស់សហមេធាវីការពារក្តី សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ទោះបីជា សំណើនេះអាចទទួលយកបានក៏ដោយ ក៏អង្គបុរេជំនុំជម្រះត្រូវតែបដិសេធវាចោលដែរ ពីព្រោះវាមាន កំហុសអង្គហេតុ អង្គច្បាប់ និងតក្កវិជ្ជា[71]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា (i) ខ្លឹមសារនៃសំណើមិនមានសង្គតភាពនិងមានភាពផ្ទុយគ្នា (ii) គ្មានការពន្យារពេលមិនសមហេតុផល

---

[67] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៦៧។

[68] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៧២។

[69] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៧២។

[70] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៧០ ដល់ ៧៣។

[71] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ១។

នៅក្នុងសំណុំរឿង ០០៣ ហើយថា (iii) ការបោះត្រា និងការតម្កល់សំណុំរឿង ០០៣ ក្នុងបណ្ណសារមិនមានយុត្តិកម្មទេ[72]។ សរុបសេចក្តីមក សហព្រះរាជអាជ្ញាអន្តរជាតិស្នើឱ្យអង្គបុរេជំនុំជម្រះបដិសេធសំណើរបស់សហមេធាវីការពារក្តី និងឱ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០៣ ដោយចេញសេចក្តីសម្រេចស្ថាពរ "ដែលទទួលបានឯកភាព" គាំទ្រដល់ការបញ្ជូន មាស មុត ទៅជំនុំជម្រះ និងចាត់វិធានការរដ្ឋបាលចាំបាច់ទាំងអស់ ដើម្បីបញ្ជូនជាបន្ទាន់នូវការពិចារណា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងឯកសារដែលនៅសេសសល់ ក្នុងសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង[73]។

33. ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិកត់សំគាល់ពីអសង្គតភាពនិងបដិភាពនៃសំណើរបស់សហមេធាវីដែលនេះជាមូលហេតុអាចនាំឱ្យអង្គបុរេជំនុំជម្រះបដិសេធសំណើនេះចោលតែម្តង[74]។ ជាក់ស្តែង យោងតាមលោកស្រីសហព្រះរាជអាជ្ញា សហមេធាវីការពារក្តីស្នើសុំឱ្យបិទបញ្ចប់សំណុំរឿងតែក្នុងករណីដែលអង្គជំនុំជម្រះមិនអាចរកសម្លេងភាគច្រើនគ្រប់គ្រាន់ ដើម្បីបញ្ជូនសំណុំរឿងនេះទៅជំនុំជម្រះ ក្នុងខណៈ ដែលអង្គបុរេជំនុំជម្រះបានឯកភាពគ្នាជាឯកច្ឆន្ទទទួលស្គាល់សុពលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយសហមេធាវីការពារក្តីក៏មិនបានជំទាស់នឹងសុពលភាពនេះដែរ[75]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ការទទួលយកលទ្ធភាពនៃការជំនុំជម្រះមួយ ដែលអាចត្រូវបានអនុម័តដោយអង្គបុរេជំនុំជម្រះ ដោយមានសម្លេងគាំទ្រភាគច្រើនគ្រប់គ្រាន់ផង សហមេធាវីការពារក្តីធ្វើឲ្យអាប់ឱនដល់ទឡ្ហីករណ៍របស់ខ្លួនពាក់ព័ន្ធនឹងការបិទបញ្ចប់សំណុំរឿង ០០៣ ជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌ[76]។

---

[72] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ២ ដល់ ២០។

[73] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ២២។

[74] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ៣។

[75] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ៣។

[76] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ៣។

34. ទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា ទឡ្ហីករណ៍របស់ មាស មុត ដែលថាកិច្ចដំណើរការនីតិវិធីបានដកហូតសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងទទួលបានសេចក្តីសម្រេចក្នុងរយៈពេលសមស្រប ពុំមានមូលដ្ឋាន និងមានភាពចម្រូងចម្រាស់ ដោយហេតុថាសហមេធាវីការពារក្តីខ្លួនឯងបានទទួលស្គាល់ថា យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិត្រូវការពេលវេលាច្រើន[77]។

35. ជាពិសេស សហព្រះរាជអាជ្ញាអន្តរជាតិបដិសេធទឡ្ហីករណ៍របស់សហមេធាវីការពារក្តីទាក់ទងនឹងអត្ថិភាពនៃការពន្យារពេលហួសហេតុ ដែលគ្មានមូលដ្ឋានទាំងផ្នែកអង្គច្បាប់ ទាំងផ្នែកអង្គហេតុ[78]។ ជាបឋម គាត់កត់សម្គាល់ថា មាស មុត ត្រូវបានជូនដំណឹងអំពីឋានៈរបស់គាត់ជាជនសង្ស័យ ដោយសហចៅក្រមស៊ើបអង្កេតបម្រុង KASPER-ANSERMET នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ពោលគឺប្រហែល ៩ ឆ្នាំកន្លងមកហើយ គឺមិនមែន ១៣ ឆ្នាំ ដូចដែលសហមេធាវីការពារក្តីលើកឡើងនោះទេ[79]។ បន្ទាប់មក ដោយផ្អែកលើវិធាន ២១ (៤) នៃវិធានផ្ទៃក្នុង និងមាត្រា ១៤ (៣) (គ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ សហព្រះរាជអាជ្ញាអន្តរជាតិបានគូសបញ្ជាក់ថាសិទ្ធិទទួលបាននីតិវិធីមួយឆាប់រហ័សមិនអាស្រ័យលើរយៈពេលនៃនីតិវិធីនេះ ឬអត្ថិភាពនៃការយឺតយ៉ាវមួយចំនួននោះទេ តែវាអាស្រ័យលើភាពសមហេតុផលនៃថិរវេលាកំណត់ជាក់ស្តែង[80] ហើយដោយអនុលោមតាមយុត្តិសាស្ត្រអន្តរជាតិ ការយឺតយ៉ាវនេះត្រូវតែវាយតម្លៃដោយផ្អែកលើកាលៈទេសៈនៃរឿងក្តី[81]។ ជាងនេះទៅទៀត ផ្ទុយពី មាស មុត សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងពីភាព

---

[77] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ៤ យោងទៅ សំណុំរឿង ០០៣ សារណារបស់ មាស មុត ស្តីពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់លើសំណុំរឿង ០០៣ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ ២០១៧ (ឯកសារ D249/2) កថាខណ្ឌ ២ និង ៣។

[78] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ៥ ដល់ ៨។

[79] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ៦។

[80] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ៧។

[81] កាលៈទេសៈទាំងនេះរួមមានភាពស្មុគស្មាញនៃកិច្ចដំណើរការនីតិវិធី អំពើប្រព្រឹត្តិរបស់ជនជាប់ចោទ អំពើប្រព្រឹត្តិរបស់អាជ្ញាធរពាក់ព័ន្ធ សូមមើល ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ៧។

ចាំបាច់ក្នុងការធ្វើឱ្យមានតុល្យភាពរវាងសិទ្ធិទទួលបានការជំនុំជម្រះ ក្នុងរយៈពេលសមស្របរបស់ជនជាប់ចោទ និងផលប្រយោជន៍យុត្តិធម៌[82]។

36. សហព្រះរាជអាជ្ញាអន្តរជាតិក៏ជំទាស់នឹងការវាយតម្លៃរបស់សហមេធាវីការពារក្តី លើភាពស្មុគស្មាញ និងភាព ធ្ងន់ធ្ងរនៃសំណុំរឿង ០០៣ ផងដែរ[83]។ លោកស្រីបញ្ជាក់ជាអាទិ៍ថា ការប្រៀបធៀបសំណុំរឿង ០០២ ទៅនឹង ០០៣ មិនមានមូលដ្ឋាន និងជាការបំភាន់ ដោយហេតុថាភាពស្មុគស្មាញ នៃសំណុំរឿង ០០៣ មិនត្រូវវាយតម្លៃដោយប្រៀបធៀបនឹងសំណុំរឿង ០០២ នោះទេ[84] គឺត្រូវវាយតម្លៃដោយពិនិត្យមើលភាពស្មុគស្មាញនៃអង្គហេតុក្នុងសំណុំរឿងដែល មាស មុត មើលស្រាល ដោយចេតនា[85] និងភាពស្មុគស្មាញនៃអង្គច្បាប់[86]។ ទាក់ទងនឹងការចោទប្រកាន់ថា ការពន្យារពេលនៃកិច្ចដំណើរការនីតិវិធីមិនមែនបណ្តាលមកពី មាស មុត សហព្រះរាជអាជ្ញាអន្តរជាតិរំលឹកជាអាទិ៍ថា ផ្ទុយទៅវិញទេ មាស មុត តាំងពីដំបូង បានបដិសេធមិនបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក ដែលជាមូលហេតុបង្ខំឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ HARMON ចោទប្រកាន់គាត់ ដោយកំបាំងមុខ[87]។

---

[82] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ៨។

[83] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ៩។

[84] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ៩។

[85] សហព្រះរាជអាជ្ញាគួសបញ្ជាក់ថាការសម្រេចមិនរាប់បញ្ចូលអង្គហេតុមួយចំនួន បានធ្វើឡើងយឺតពេលទៅហើយ លោកស្រីក៏សង្កត់ធ្ងន់លើភាពស្មុគស្មាញនៃការស៊ើបអង្កេតដែលពាក់ព័ន្ធនឹងកងទ័ពបដិវត្តន៍កម្ពុជាទាំងមូល ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយសមាជិកកងទ័ពជើងទឹក និងកងទ័ពអាកាស នៅទូទាំងទឹកដីកម្ពុជាក្រោមរបបកម្ពុជាប្រជាធិបតេយ្យសូមមើលចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ១០។

[86] សហព្រះរាជអាជ្ញាលើកឡើងជាអាទិ៍អំពីការកំណត់ប្រភេទបទល្មើសជាច្រើន អំពីការខ្វែងគំនិតគ្នា អំពីបញ្ហាច្បាប់ថ្មីដែល បានលើកឡើង ក៏ដូចជាភាពចាំបាច់ក្នុងការពិនិត្យឡើងវិញនូវភស្តុតាងក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក (“សំណុំរឿង ០០១”) និង សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក (“សំណុំរឿង ០០២”) សូមមើល ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ១១។

[87] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ១២។

37. បន្ថែមពីលើការអះអាងថា មាស មុត មិនបង្ហាញពីអត្ថិភាពនៃការមាក់ងាយដែលគាត់អះអាងថាបានទទួលរងអស់រយៈពេល១៣ឆ្នាំ ដោយសារតែកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក[88] សហព្រះរាជអាជ្ញាអន្តរជាតិចង្អុលបង្ហាញថា មាស មុត សន្មតដោយភាន់ច្រឡំថា កិច្ចដំណើរការនីតិវិធីនាពេលអនាគតប្រឆាំងនឹងរូបគាត់នៅក្នុងដំណាក់កាលជំនុំជម្រះ នឹងបង្កឱ្យមានការរំលោភសិទ្ធិរបស់គាត់ក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីឆាប់រហ័ស ពីព្រោះថា សិទ្ធិមួយមិនអាចចាត់ទុកថាត្រូវបានរំលោភបំពាន *មុនពេល*ការរំលោភបំពានបានកើតឡើងនោះទេ[89]។ នៅទីបញ្ចប់ សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់នឹងសេចក្តីសន្និដ្ឋានរបស់ មាស មុត លើយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិទាក់ទងនឹងការពន្យារពេលមិនត្រឹមត្រូវ[90] ហើយអះអាងថាការប្រៀបធៀបនឹងការអនុវត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន និងតុលាការព្រហ្មទណ្ឌអន្តរជាតិ បង្ហាញឱ្យឃើញថាកិច្ចដំណើរការនីតិវិធីតុលាការដែលមានថិរវេលាស្រដៀងគ្នានឹងថិរវេលានៃសំណុំរឿង ០០៣ មិនត្រូវបានចាត់ទុកថាមិនសមរម្យនោះទេ ក្នុងខណៈជនជាប់ចោទកំពុងជាប់ឃុំទៀតផង[91]។

38. ទីបី សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា មាស មុត សន្និដ្ឋានដោយភាន់ច្រឡំថា ការរំលោភបំពានលើកិច្ចដំណើរការនីតិវិធីរងការចោទប្រកាន់ ជាយុត្តិកម្មនៃការបិទបញ្ចប់សំណុំរឿង[92]។ លោកស្រីយល់ឃើញថា មាស មុត លើកឡើងតែពីគោលការណ៍រំលោភបំពានលើកិច្ចដំណើរការ

---

[88] សហព្រះរាជអាជ្ញាពន្យល់ថាខណៈដែលមាស មុត ត្រូវគោរពតាមបែបបទផ្លូវការមួយចំនួនសម្រាប់រាយការណ៍ទៅ អ.វ.ត.ក មាស មុត បានធ្វើដំណើរជាទៀងទាត់ទៅកាន់ប្រទេសថៃ ដោយមិនមានលិខិតឆ្លងដែន ដើម្បីទទួលការព្យាបាលជំងឺ ហើយបាន ទទួលលិខិតឆ្លងដែនថ្មីនៅឆ្នាំ ២០១៦ ដោយមិនបានជូនដំណឹងដល់ អ.វ.ត.ក។ គាត់ថែមទាំងបានចូលរួមនៅក្នុងពិធីបុណ្យ សពរបស់ នួន ជា ទៀតផង។ សូមមើលចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ D272/1 កថាខណ្ឌ១៣ កំណត់ត្រាយោងជើង ទំព័រ ៧៤ និង ៧៥។

[89] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ១៤។

[90] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ១៦។

[91] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ១៦។

[92] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ១៧។

នីតិវិធីតែមួយគត់ ដោយហេតុថា មាស មុត ដឹងថាក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក មិនបានរាប់បញ្ចូលការរំលត់បណ្តឹងអាជ្ញា ដោយឈរលើមូលដ្ឋានផ្សេងៗទៀតនោះទេ[93]។ លោកស្រីបញ្ជាក់បន្ថែមថា មាស មុត មិនបានវាស់វែងវិសាលភាពនៃគោលការណ៍រំលោភបំពានលើកិច្ចដំណើរការនីតិវិធី ហើយថាការចោទប្រកាន់របស់គាត់ មិនឈានដល់កម្រិតខ្ពស់ដល់ថ្នាក់រំលត់បណ្តឹងអាជ្ញានោះទេ[94]។ យោងតាមវិធាន ២១ (១) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិចង្អុលបង្ហាញថា ការបញ្ចប់កិច្ចដំណើរការនីតិវិធី មិនសមាមាត្រទៅនឹងព្យសនកម្មដែល មាស មុត អះអាងថាខ្លួនបានទទួលរងឡើយ។ លោកស្រីទាមទារឱ្យមានតុល្យភាពរវាងសិទ្ធិរបស់ភាគី*ទាំងអស់*[95]។ សរុបសេចក្តីមក លោកស្រីគូសបញ្ជាក់ថា ការបិទកិច្ចដំណើរការនីតិវិធី ដោយមូលហេតុដែលមិនទាក់ទងនឹងអង្គសេចក្តីក្នុងសំណុំរឿង ០០៣ នឹងមិនអាចឱ្យ មាស មុត ការពារកេរ្តិ៍ឈ្មោះខ្លួនបានឡើយ គឺវាខុសពីការដែលគាត់ចូលរួមក្នុងការជំនុំជម្រះមួយដែលគាត់ត្រូវបានផ្តល់ឱកាស តតាំងបដិសេធដីកាចោទប្រកាន់ដែលមិនអាចប្រកែកបានជាសន្ទត[96]។

## ខ. ឧត្តិ៍ករណ៍របស់ភាគីចំពោះសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

### ១. សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

39. នៅក្នុងសំណើរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ការពិចារណារបស់អង្គបុរេជំនុំជម្រះមានកំហុសអង្គច្បាប់ដែលបណ្តាលឱ្យមានភាពអយុត្តិធម៌យ៉ាងជាក់ស្តែង[97] ហើយជាថ្មីម្តងទៀត អង្គជំនុំជម្រះបានដាក់ការចោទប្រកាន់របស់សហព្រះរាជអាជ្ញាក្នុងស្ថានភាពមួយមិនច្បាស់លាស់ ដោយ

[93] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ១៧។

[94] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ១៨។

[95] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ១៩ និង ២០។

[96] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D272/1) កថាខណ្ឌ ២០។

[97] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) ) កថាខណ្ឌ ១១។

មូលហេតុដូចខាងក្រោម[98]។ លោកស្រីយល់ថា អង្គបុរេជំនុំជម្រះមានកាតព្វកិច្ច (i) ចេញសេចក្តីសម្រេចដើម្បីបញ្ចប់ដំបិទណាក់កាលមុនការជំនុំជម្រះនៃនីតិវិធីក្នុងសំណុំរឿង ០០៣ ស្របតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក (ii) បញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើការសន្និដ្ឋានជាឯកច្ឆ័ន្ទរបស់ខ្លួនដែលថាដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព (iii) ហើយជាជម្រើស បញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅអង្គជំនុំជម្រះសាលាដំបូង ស្របតាមវិធាន ៧៧ (១៣) (ខ) នៃវិធានផ្ទៃក្នុង[99]។ ដោយផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឱ្យអង្គបុរេជំនុំជម្រះ បិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះសំណុំរឿង ០០៣ តាមរយៈការចេញសេចក្តីសម្រេចជាស្ថាពរ និងរួមគ្នាមួយដែលគាំទ្រដល់ការបញ្ជូន មាស មុត ទៅជំនុំជម្រះ ព្រមទាំងចាត់វិធានការរដ្ឋបាលចាំបាច់នានា ដើម្បីបញ្ជូនជាបន្ទាន់ការពិចារណា ដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ និងឯកសារដែលនៅសេសសល់ក្នុងសំណុំរឿងនេះទៅកាន់អង្គជំនុំជម្រះសាលាដំបូង[100]។

40. ជាបឋម សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អង្គបុរេជំនុំជម្រះជាប់កាតព្វកិច្ចចេញសេចក្តីសម្រេចបិទបញ្ចប់ជាស្ថាពរនូវដំណាក់មុនការជំនុំជម្រះនៃសំណុំរឿង ០០៣។ លោកស្រីអះអាងថា អង្គបុរេជំនុំជម្រះបានប្រព្រឹត្តខុសអង្គច្បាប់ ដោយខកខានមិនបានចេញសេចក្តីសម្រេចជាស្ថាពរមួយដែល អនុម័តដោយចៅក្រមទាំង៥រូបនៃអង្គបុរេជំនុំជម្រះ ដោយរៀបរាប់លម្អិតអំពីជំហាននីតិវិធីជាបន្ត បន្ទាប់ស្របតាមសេចក្តីសម្រេច*ទាំងអស់*ដែលបានអនុម័តដោយចៅក្រមអង្គបុរេជំនុំជម្រះ[101]។ យោងតាមសហព្រះរាជអាជ្ញាអន្តរជាតិ ការខកខានឬការបដិសេធរបស់អង្គបុរេជំនុំជម្រះក្នុងការចេញសេចក្តី

---

[98] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ D271/1 កថាខណ្ឌ ១១។

[99] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ១០ ដល់ ៣១។

[100] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ៣៤។

[101] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ១២។

សម្រេចជាស្ថាពរមួយ បានបង្កការជាប់គាំងផ្នែកផ្លូវច្បាប់ ដែលបំផ្លាញប្រព័ន្ធតុលាការនៃ អ.វ.ត.ក[102]។

41. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា *គ្រប់*ភាគីទាំងអស់ក្នុងសំណុំរឿង ០០៣ មានសិទ្ធិទទួលបាន ដំណោះស្រាយតាមផ្លូវតុលាការ ប្រកបដោយយុត្តិធម៌និងឆាប់រហ័ស លើបណ្ដឹងឧទ្ធរណ៍ដែលខ្លួនបាន ដាក់នៅក្នុងដំណាក់កាលមុនការជំនុំជម្រះ ដើម្បីផ្ដល់តម្លាភាព និងសច្ចភាពគតិយុត្ត[103]។ លោកស្រី ចង្អុលបង្ហាញថា អង្គបុរេជំនុំជម្រះគឺជា "ស្ថាប័នតែមួយគត់ដែលមានសិទ្ធិអំណាចក្នុងការអារកាត់ជា ចុងក្រោយ" លើរាល់បញ្ហាមុខដំណាក់កាលជំនុំជម្រះ[104] ហើយអាស្រ័យហេតុនេះ អង្គជំនុំជម្រះត្រូវតែ បំពេញតាមកាតព្វកិច្ចគតិយុត្តិដែលត្រូវបានទទួលយកជាសកល ក្នុងការសម្រេចលើបញ្ហាវិវាទ *ទាំង អស់* ដោយមិនផ្ដោតលើភាពស្មុគស្មាញ ឬមិនស្មុគស្មាញនៃវិវាទទាំងនេះឡើយ ហើយត្រូវផ្ដល់ជូន ដំណោះស្រាយផ្លូវច្បាប់យ៉ាងឆាប់រហ័សដើម្បីចៀសវាងយុត្តិនីសេធ[105]។ សហព្រះរាជអាជ្ញាអន្តរជាតិ អះអាងថា ហេតុនេះ ចៅក្រមនៃអង្គបុរេជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ តាមរយៈការសម្ដែង មតិដាច់ដោយឡែកពីគ្នា ជំនួសឱ្យសេចក្ដីសម្រេចរួមគ្នានិងជាស្ថាពរមួយ ដោយកំណត់នីតិវិធីជា បន្តបន្ទាប់ដែលត្រូវអនុវត្តក្នុងសំណុំរឿងនេះ ដែលបណ្ដាលឱ្យមានភាពអយុត្តិធម៌យ៉ាងជាក់ស្ដែង[106]។

---

[102] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ១៣។

[103] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ១៤ យោងទៅ សំណុំរឿង ០០៤/២ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង០០៤/២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2 ("សំណុំរឿង ០០៤/២ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ E004/2/1/1/2)")។ សំណុំរឿង ០០៣ សេចក្ដីសម្រេចលើសំណើរបស់ មាស មុត សុំការបំភ្លឺពាក់ព័ន្ធនឹងសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះទៅលើបណ្ដឹងសាទុក្ខប្រឆាំងនឹងដីកាដំណោះស្រាយ ដែលបានចេញក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ ឯកសារ D266/24 និង D267/32 កថាខណ្ឌ ៣១។ សំណុំរឿង ០០៤/២ សេចក្ដីពិចារណាទាក់ទងនឹងបណ្ដឹងសាទុក្ខប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៤៦, ៥១, ៥៤ និង ៦៨។

[104] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ១៥។

[105] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ១៥។

[106] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ១៧។

42. ទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អង្គបុរេជំនុំជម្រះជាប់កាតព្វកិច្ចបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ ពីព្រោះខ្លួនបានសម្រេចតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះជាឯកច្ឆន្ទ។ សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា អវត្តមាននៃសម្អាងហេតុរួមគ្នារបស់ចៅក្រមទាំងអស់នៃអង្គបុរេជំនុំជម្រះ មិនប៉ះពាល់ដល់ឯកច្ឆន្ទភាពនៃសេចក្តីសម្រេចថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព[107] ដោយហេតុថា ម៉្យាង ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក អនុញ្ញាតឱ្យដាក់បញ្ចូលគ្នានូវមតិដាច់ដោយឡែក ហើយម្យ៉ាងវិញទៀត អត្ថិភាពនៃមូលដ្ឋានរួមគ្នាមិនមែនជាលក្ខខណ្ឌតម្រូវសម្រាប់ការប្រកាសសេចក្តីសម្រេចរួមគ្នានៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិឡើយ[108]។

43. ចំពោះសេចក្តីប្រកាសរបស់ប្រធានអង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២ ថា មានតែផ្នែកសម្រេចសេចក្តី ដែលត្រូវបានព្រមព្រៀងជាឯកច្ឆន្ទ និងចុះហត្ថលេខាដោយចៅក្រមទាំងប្រាំរូបប៉ុណ្ណោះ ទើបមានអានុភាពចងកាតព្វកិច្ច សហព្រះរាជអាជ្ញាអន្តរជាតិគូសបញ្ជាក់ថា កាលពីមុន អង្គបុរេជំនុំជម្រះធ្លាប់បានចេញសេចក្តីសម្រេចចងកាតព្វកិច្ច ដោយគ្មានផ្នែកសម្រេចសេចក្តីជាឯកច្ឆ័ន្ទ រួមទាំងសេចក្តីសម្រេចមិនមានសំឡេងគាំទ្រគ្រប់គ្រាន់ផងដែរ[109]។ ទោះជាយ៉ាងនេះក្តី ចៅក្រមទាំងប្រាំរូបនៃអង្គបុរេជំនុំជម្រះបានចុះហត្ថលេខាលើផ្នែកនានានៃសេចក្តីពិចារណា ដោយបានឯកភាពគ្នាថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព[110]។ សហព្រះរាជអាជ្ញាអន្តរជាតិបន្ថែមទៀតថា ការបកស្រាយណាមួយដែលមិនគិតដល់អានុភាពចងកាតព្វកិច្ចនៃការរកឃើញជាក់ច្បាស់របស់ចៅក្រមទាំងប្រាំរូបនៃអង្គបុរេជំនុំជម្រះ ដែលថាដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព គឺមិនគោរពភាពសមហេតុផល និងឲ្យតម្លៃលើទម្រង់ជាជាងខ្លឹមសារ[111]។ ដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា ចៅក្រមនៃអង្គបុរេជំនុំជម្រះមានភារកិច្ចអនុវត្តសេចក្តីសន្និដ្ឋានជាឯកច្ឆ័ន្ទរបស់ខ្លួន តាមរយៈការចេញសេចក្តីសម្រេច

---

[107] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ១៨ និង១៩។

[108] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ (D271/1) កថាខណ្ឌ ១៨ និង១៩។

[109] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ២០។

[110] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ២០។

[111] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ២១។

ស្ពាក្យពរមួយ ដែលបញ្ជាក់ថា មាស មុត ត្រូវតែបញ្ជូនទៅជំនុំជម្រះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[112]។

44. ទីបី សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា បើទោះជាអង្គបុរេជំនុំជម្រះសម្រេចមិនអើពើនឹងសេចក្តីសន្និដ្ឋានជាឯកច្ឆន្ទរបស់ខ្លួនផ្ទាល់ក៏ដោយ ក៏អង្គបុរេជំនុំជម្រះត្រូវតែបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង[113]។ ដោយហេតុថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានធ្វើមោឃភាពដោយសំឡេងភាគច្រើនលើសលប់ អង្គបុរេជំនុំជម្រះត្រូវតែបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងអនុលោមតាម គោលជំហរជាក់ស្តែង គឺថា នីតិវិធីស៊ើបអង្កេត ឬចោទប្រកាន់ ត្រូវបន្តទៅមុខ[114]។

45. សហព្រះរាជអាជ្ញាអន្តរជាតិឈានដល់ការសន្និដ្ឋានបែបនេះ ដោយផ្អែកលើទឡ្ហីករណ៍ជាច្រើន។ ជាបឋម សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អង្គបុរេជំនុំជម្រះយល់ឃើញថា ក្នុងរឿងក្តីនេះ "គោលជំហរស្វ័យប្រវត្តិ" ត្រូវបានចែងឡើងយ៉ាងច្បាស់ ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត អំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក លើ មាស មុត[115]។ លើសពីនេះទៀត សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា "គោលជំហរស្វ័យប្រវត្តិ" មានសារៈសំខាន់ដល់ការបំពេញវត្ថុបំណងរបស់ អ.វ.ត.ក ដោយអនុវត្តតាមកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា ក្នុងការស៊ើបអង្កេត និងកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម[116]។ ដោយយោងដល់យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ សហព្រះរាជអាជ្ញាអន្តរជាតិសង្កត់ធ្ងន់ថា

---

[112] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ២១។

[113] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ២២។

[114] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ២២-៣១។

[115] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ២៤។

[116] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ២៥។

ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក មិនអនុញ្ញាតឱ្យការខ្វែងយោបល់គ្នានេះនៅបន្តគេចផុតពីដំណោះស្រាយប្រកបដោយប្រសិទ្ធភាពមួយនោះឡើយ[117]។

46. បន្ទាប់មកទៀត សហព្រះរាជអាជ្ញាអន្តរជាតិប្រកាសថា យោងតាមកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក "មុខងារចម្បងដែលផ្តល់ជូនអង្គបុរេជំនុំជម្រះ ច្បាស់ណាស់ គឺស្វែងរកយន្តការប្រកបដោយប្រសិទ្ធភាព ដើម្បីដោះស្រាយជាស្ថាពរនូវការខ្វែងយោបល់គ្នា [...] រវាងសហចៅក្រមស៊ើបអង្កេត" [118]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អង្គបុរេជំនុំជម្រះមានយុត្តាធិការជាប់មកជាមួយ ដើម្បីដោះស្រាយបញ្ហាច្បាប់ ក្នុងករណីក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក មិនបានចែងជាក់លាក់អំពីអំណាចសម្រេច ប្រសិនបើយុត្តាធិការនេះមានសមិតភាពជាមួយនឹង (១) មុខងារដែលផ្តល់ជូនដោយអត្ថបទច្បាប់របស់ អ.វ.ត.ក ដើម្បីជាប្រយោជន៍យុត្តិធម៌ (២) កាតព្វកិច្ចក្នុងការ "ការពារផលប្រយោជន៍របស់ជនត្រូវចោទ និងធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើការនីតិវិធីដោយយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ" និង (៣) តម្រូវការចាំបាច់ ក្នុងការធានាបាននូវកិច្ចការរដ្ឋបាលតុលាការល្អ និងត្រឹមត្រូវយុត្តិធម៌[119]។ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា អង្គបុរេជំនុំជម្រះមានកាតព្វកិច្ចដោះស្រាយការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត ទោះជាក្រោមទម្រង់បែបណាក៏ដោយ (តាមរយៈការខ្វែងយោបល់គ្នាជាផ្លូវការ ឬបណ្តឹងឧទ្ធរណ៍របស់ភាគី)[120]។

---

[117] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ២៦ យោងទៅ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) កថាខណ្ឌ ១០១។ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១១៩ និង ១២៣។

[118] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ២៧។

[119] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ២៧។ សូមមើលផងដែរ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ២៨ (ដើម្បីគាំទ្រដល់ការវិភាគរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ថាមានការរំពឹងទុកប្រហាក់ប្រហែលគ្នាពីសភាចោទប្រកាន់ពិសេស នៃតុលាការព្រហ្មទណ្ឌពិសេសអាហ្វ្រិកកណ្តាល នូវដំណោះស្រាយឆាប់រហ័ស និងជាស្ថាពរ ចំពោះការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត)។

[120] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ២៧។

01676412



47. ក្រៅពីនេះទៀត សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ស្ថានភាពបច្ចុប្បន្នប្រៀបបាននឹងស្ថានភាពរបស់អង្គជំនុំជម្រះនៃតុលាការអន្តរជាតិនានា ដែលមានចំនួនចៅក្រមស្មើគ្នា ដែលមានយន្តការ "គោលជំហរស្វ័យប្រវត្តិ" ដែលត្រូវផ្តួចផ្តើមដោយចៅក្រម ពេលមិនអាចរកសំឡេងភាគច្រើនចាំបាច់បាន[121]។ ទោះជាក្នុងករណីណាក៏ដោយ ការមិនព្រមព្រៀងគ្នារវាងចៅក្រមមិននាំឲ្យមានការលើកលែងការចោទប្រកាន់ ជាស្វ័យប្រវត្តិ នៅក្នុងតុលាការទាំងនេះទេ[122]។

48. អាស្រ័យហេតុដូចបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិប្រកាសថា ចៅក្រមជាតិមិនត្រូវបានអនុញ្ញាតឲ្យមើលរំលង "គោលជំហរស្វ័យប្រវត្តិ" នេះទេ[123]។ ដោយរំឭកថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាកម្រិតអំពីមូលហេតុតិចតួចនៃការរលត់បណ្តឹងអាជ្ញា ព្រមទាំងករណីយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលទៅលើករណីនេះ សហព្រះរាជអាជ្ញាអន្តរជាតិបញ្ជាក់ថា សច្ចធារណ៍និរទោស និងគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* មិនអាចនាំទៅដល់ការលើកលែងការចោទប្រកាន់ឡើយ ជាពិសេស ក្នុងករណីដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព[124]។ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា ប្រសិនបើមិនគោរពតាមកាតព្វកិច្ចតុលាការ អង្គបុរេជំនុំជម្រះធ្វើឲ្យប្រព័ន្ធយុត្តិធម៌នៃ អ.វ.ត.ក ទន់ខ្សោយ ហើយ មាស មុត ទទួលបាននិទណ្ឌភាពដោយអយុត្តិធម៌ ចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុត[125]។

## ២. ចម្លើយតបរបស់សហមេធាវីការពារក្តី

49. នៅក្នុងចម្លើយតបរបស់ខ្លួន សហមេធាវីការពារក្តីលើកឡើងថា សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិមិនអាចទទួលយកបានទេ ពីព្រោះអង្គបុរេជំនុំជម្រះមិនបានសម្រេចជាឯកច្ឆន្ទតម្កល់ដីកាបញ្ជូន

---

[121] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ២៩។

[122] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ២៩។

[123] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ៣០។

[124] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ៣០។

[125] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ៣២។

រឿងទៅជំនុំជម្រះ[126] ហើយចេតនារបស់ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះមិនមានភាពច្បាស់លាស់[127] ។ ជាក់ស្តែង សហមេធាវីការពារក្តីអះអាងថា (១) ការតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះជាឯកច្ឆន្ទ ដោយអង្គបុរេជំនុំជម្រះមានភាពមិនប្រាកដប្រជា និង (២) ទោះបីអង្គជំនុំជម្រះតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះជាឯកច្ឆ័ន្ទក៏ដោយ ក៏ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក មិនបានកំណត់ថា ដីកានេះមានអានុភាពលើដីកាលើកលែងចោទប្រកាន់និងនាំឲ្យបញ្ជូន សំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងឡើយ[128]។ ដូច្នេះ សហមេធាវីការពារក្តីស្នើសុំឲ្យអង្គបុរេជំនុំជម្រះបញ្ឈប់ការជាប់គាំងបច្ចុប្បន្ន ដែលរំលោភលើសិទ្ធិរបស់ មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងធ្វើឲ្យអាប់ឱនដល់សុចរិតភាព និងកេរដំណែលរបស់ អ.វ.ត.ក[129]។ ទោះបីជាសំណើនេះមិនអាចទទួលយកបាន និងត្រូវច្រានចោលភ្លាមៗក្តី[130] ក៏សហមេធាវីការពារក្តីមិនជំទាស់នឹងការពិនិត្យរបស់អង្គបុរេជំនុំជម្រះ ដោយសារតែភាពជាប់គាំងរបស់តុលាការនាពេលបច្ចុប្បន្ន ប៉ុន្តែ ទាមទារឲ្យអង្គបុរេជំនុំជម្រះបដិសេធសំណើនេះ ព្រមទាំងបិទបញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ[131]។

50. ជាដំបូង សហមេធាវីការពារក្តីលើកឡើងថា សហព្រះរាជអាជ្ញាអន្តរជាតិអះអាងដោយភាន់ច្រឡំថា អង្គបុរេជំនុំជម្រះមានកាតព្វកិច្ចបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីមានការសន្និដ្ឋាន "ជាឯកច្ឆ័ន្ទ" ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព[132]។ តាមរយៈការប្រៀបធៀបយោបល់ដោយឡែករបស់ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ និងសេចក្តីពិចារណារួម សហមេធាវី

---

[126] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) ទំព័រ ១។

[127] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) ទំព័រ ១។

[128] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ៦-៣៥។

[129] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ៣៥។

[130] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ៥។

[131] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ៣៥។

[132] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ៦ យោងដល់សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ១២-២១។

ការពារក្ដីចោទសួរថា តើចៅក្រមជាតិពិតជាយល់ខ្លឹមសារទាំងស្រុង និងបរិបទនៃសេចក្ដីសន្និដ្ឋានជាឯកច្ឆ័ន្ទ ដែរឬទេ[133]។ សហមេធាវីការពារក្ដីកត់សម្គាល់ថា ត្រង់ចំណុចជាសារវ័ន្ត និងជាកត្តាកំណត់ យោបល់ដោយឡែករបស់ចៅក្រមជាតិបែរជាមិនស្របគ្នានឹងសេចក្ដីពិចារណារួមទៅវិញ ហើយសហមេធាវីការពារក្ដីបញ្ជាក់ថា ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះត្រូវតែបំភ្លឺអំពីអសង្គតិភាពទាំងនេះ[134]។

51. ទីមួយ សហមេធាវីការពារក្ដីចោទសួរថា តើចៅក្រមជាតិមានចេតនាចោទប្រកាន់សហចៅក្រមស៊ើបអង្កេតពីបទរារាំងដល់កិច្ចការតុលាការ ពាក់ព័ន្ធនឹងសេចក្ដីសម្រេចរបស់ពួកគេដែលគេចវេះពីយន្តការដោះស្រាយការខ្វែងយោបល់គ្នា តើដីកាដំណោះស្រាយផ្ទុយគ្នាអាចចាត់ទុកជាការខ្វែងយោបល់គ្នាមិនដោះស្រាយដែរឬទេ តើចៅក្រមជាតិបានចូលរួមក្នុងការពិភាក្សាសម្រេច និងតាក់តែងសេចក្ដីពិចារណារួម ដែរឬទេ[135]។

52. ទីពីរ សហមេធាវីការពារក្ដីងឿងឆ្ងល់អំពីមតិរបស់ចៅក្រមជាតិពាក់ព័ន្ធនឹងការអនុវត្តវិធាន ៧៧(១៣) នៃផ្ទៃក្នុង ចំពោះដីកាដំណោះស្រាយផ្ទុយគ្នា[136]។ សហមេធាវីការពារក្ដីកត់សម្គាល់ថា ចៅក្រមជាតិយល់ឃើញនៅក្នុងសំណុំរឿងថា "តាមវិធាន ៧៧(១៣) [...] ដីកាដំណោះស្រាយទាំងពីរមានតម្លៃស្មើគ្នា និងមានសុពលភាពដូចគ្នា"[137] ដោយមិនបានផ្ដល់សំអាងហេតុចំពោះការងាកចេញពីវិធីសាស្ត្រ

---

[133] ចម្លើយតបរបស់សហមេធាវីការពារក្ដី (ឯកសារ D271/3) កថាខណ្ឌ ៦។

[134] ចម្លើយតបរបស់សហមេធាវីការពារក្ដី (ឯកសារ D271/3) កថាខណ្ឌ ៦-២៥។

[135] ជាពិសេស សហមេធាវីការពារក្ដីកត់សម្គាល់ថា យោបល់ដោយឡែករបស់ចៅក្រមជាតិមិនប្រើភាសាជូរចត់នៃសេចក្ដីពិចារណារួមនោះទេ ដោយកត់សម្គាល់ទៅលើសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការរក្សាទុកការខ្វែងយោបល់គ្នាក្នុងការិយាល័យរបស់ខ្លួន ចៅក្រមជាតិបានសម្រេចថា អង្គបុរេជំនុំជម្រះពុំអាច "អនុវត្តយុត្តាធិការរបស់ខ្លួន ដូចមានចែងក្នុងវិធាន ៧២" ដោយសន្និដ្ឋានថា ដីកាដំណោះស្រាយទាំងពីរមានតម្លៃស្មើគ្នា និងមានសុពលភាពដូចគ្នា។ សូមមើលចម្លើយតបរបស់សហមេធាវីការពារក្ដី (ឯកសារ D271/3) កថាខណ្ឌ ៧-១០។

[136] ចម្លើយតបរបស់សហមេធាវីការពារក្ដី (ឯកសារ D271/3) កថាខណ្ឌ ១១-១៤។

[137] ចម្លើយតបរបស់សហមេធាវីការពារក្ដី (ឯកសារ D271/3) កថាខណ្ឌ ១២ យោងទៅ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) កថាខណ្ឌ ១១៥។

របស់ខ្លួន ក្នុងសំណុំរឿង ០០៤/២ ដែលសម្រេចតម្កល់ដីកាលើកលែងចោទប្រកាន់ទុកជាដំណោះស្រាយដ៏សមស្របបំផុត ដោយសារតែចន្លោះប្រហោងនៃវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង[138]។

53. ទីបី សហមេធាវីការពារក្តីលើកឡើងថា វិធីសាស្ត្ររបស់ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ ចំពោះការអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* មានភាពមិនស៊ីសង្វាក់គ្នា[139]។ ទោះបីជាមានសេចក្តីសន្និដ្ឋានជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះបដិសេធការអនុវត្តគោលការណ៍នេះក្នុងសេចក្តីពិចារណាលើសំណុំរឿង ០០៣ ក៏ដោយ[140] ក៏សហមេធាវីការពារក្តីអះអាងថា ចៅក្រមជាតិហាក់ដូចជាអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដោយបានសន្និដ្ឋានថាសំណុំរឿង ០០៣ ត្រូវដាក់បញ្ចូលទៅក្នុងបណ្ណសារ[141]។

54. ទីបួន សហមេធាវីការពារក្តីចោទសួរថា តើចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះពិតជាមានចេតនាតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែរឬទេ ខណៈដែលខ្លួនយល់ឃើញថា មាស មុត មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[142]។ បើគ្មានសេចក្តីសន្និដ្ឋានជាឯកច្ឆន្ទលើបញ្ហាយុត្តាធិការបុគ្គល និងបើគ្មានការវិភាគរបស់ខ្លួនលើចំណុចនេះ[143] សហមេធាវីការពារក្តីអះអាងថា ចៅក្រមជាតិបានបញ្ជាក់

---

[138] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ១២-១៤។

[139] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ១៥ និង ២១។

[140] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ១៥ យោងទៅ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) កថាខណ្ឌ ៧៧។

[141] ផ្អែកលើការចោទប្រកាន់លើសហចៅក្រមស៊ើបអង្កេត សហមេធាវីការពារក្តីអះអាងថា តាមពិត ចៅក្រមជាតិបានអនុវត្តតាមទឡ្ហីករណ៍របស់ពួកគេដែលថា (១) អង្គបុរេជំនុំជម្រះមិនអាចអនុវត្តយុត្តាធិការរបស់ខ្លួន ដូចមានចែងក្នុងវិធាន ៧២ (២) អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ដីកាដំណោះស្រាយទាំងពីរមានតម្លៃស្មើគ្នា និងមានសុពលភាពដូចគ្នា និង (៣) គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ជាមូលដ្ឋាននៃគោលការណ៍សច្ចធារណ៍និរទោស មិនអាចឲ្យសន្និដ្ឋានថា កិច្ចរបស់សហចៅក្រមស៊ើបអង្កេតណាម្នាក់មានឧត្តមានុភាពឡើយ។ សូមមើលចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ១៥-២០។

[142] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ២២-២៤។

[143] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ២២ និង ២៣។

ជាថ្មី ក្នុងអំឡុងកិច្ចស៊ើបសួរ ថា មាស មុត មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ និង បានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ក្នុងសំណុំរឿង ០០៣[144]។

55. ដោយសារអសង្គតិភាពទាំងនេះ សហមេធាវីការពារក្តីអះអាងថា ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះត្រូវបំភ្លឺអំពីគោលជំហររបស់ខ្លួន នៅក្នុងសេចក្តីពិចារណា[145]។ ជាពិសេស មេធាវីការពារក្តីលើកឡើងថា ប្រសិនបើចៅក្រមជាតិទទួលស្គាល់ថា ដីកាលើកលែងចោទប្រកាន់មិនត្រូវបដិសេធចោល វានឹងមានការជាប់គាំងខាងវិធារណកិច្ចដែលត្រូវដោះស្រាយ តាមរយៈសេចក្តីសម្រេចចុងក្រោយ ដើម្បីបិទបញ្ចប់ និងដាក់បញ្ចូលសំណុំរឿងទៅក្នុងបណ្ណសារ[146]។

56. បន្ទាប់មកទៀត សហមេធាវីការពារក្តីលើកឡើងថា សហព្រះរាជអាជ្ញាអន្តរជាតិអះអាងដោយភាន់ច្រឡំថា (១) អង្គបុរេជំនុំជម្រះមានកាតព្វកិច្ចបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ផ្អែកលើការយល់ឃើញជាឯកច្ឆន្ទថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព និង (២) ការបញ្ជូនទៅជំនុំជម្រះនេះមានហេតុផលត្រឹមត្រូវ បើទោះជាអង្គបុរេជំនុំជម្រះសម្រេចមិនអើពើចំពោះការយល់ឃើញជាឯកច្ឆន្ទរបស់ខ្លួនក្តី[147]។ ផ្អែកលើយុត្តិសាស្ត្ររបស់ អ.វ.ត.ក[148] សហមេធាវីការពារក្តីសន្មតថា ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះហាក់ដូចជាយល់ឃើញថា គោលជំហរស្វ័យប្រវត្តិមិនអាចអនុវត្តចំពោះរឿងក្តីនេះ ពីព្រោះចៅក្រមជាតិបានប្រកាសថា អង្គបុរេជំនុំជម្រះមិនអាចអនុវត្តយុត្តាធិការ

---

[144] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ២៣។

[145] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ២៥។

[146] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ២៥។

[147] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ២៦ យោងដល់សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ២២។

[148] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ២៧ យោងជាពិសេសទៅ សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៦៥។ សំណុំរឿង ០០២ (អបជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ២៧៤។

របស់ខ្លួន តាមវិធាន ៧២ បានឡើយ[149]។ សហមេធាវីការពារក្តីសន្និដ្ឋានថា ដូច្នេះ ដីកាដំណោះស្រាយទាំងពីរជាការរំលោភបំពានលើសិទ្ធិរបស់ មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ហើយដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនអាចត្រូវបានជំទាស់បាន ដែលផ្ទុយនឹងលក្ខខណ្ឌតម្រូវជាមូលដ្ឋាននៃនីតិរដ្ឋ[150]។ សហមេធាវីការពារក្តីបន្ថែមទៀតថា ភាគីនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ពិតជាមិនបានឯកភាពគ្នាលើគោលជំហរស្វ័យប្រវត្តិមួយ ដែលនាំឲ្យមានការបញ្ជូនរឿងទៅជំនុំជម្រះជាប្រព័ន្ធ នៅពេលដីកាលើកលែងចោទប្រកាន់ត្រូវបានចេញក្នុងពេលជាមួយគ្នា ពីព្រោះគោលជំហរនេះរំលោភលើគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* [151]។

57. ក្រៅពីនេះទៀត សហមេធាវីការពារក្តីអះអាងថា វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង មិនអាចអនុវត្តបានទេ នៅពេលសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា[152]។ សហមេធាវីការពារក្តីលើកឡើងថា ការអនុវត្តរួមគ្នានូវវិធាន ៧៧(១៣)(ក) និងវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង នាំទៅរកលទ្ធផលមិនសមទំនង និងបង្កឲ្យមានព្យសនកម្មមិនអាចជួសជុលបានចំពោះសិទ្ធិរបស់ មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដោយសារតែដីកាដំណោះស្រាយទាំងពីរនឹងតាមផ្តន្ទាគាត់ ជារៀងរហូត[153]។

58. ម្យ៉ាងវិញទៀត សហមេធាវីការពារក្តីជំទាស់នឹងការបកស្រាយវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានអានុភាពជាស្វ័យប្រវត្តិលើដីកាលើកលែងចោទប្រកាន់ ពីព្រោះការបកស្រាយបែបនេះរំលោភលើគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*

---

[149] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ២៧ យោងដល់សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) កថាខណ្ឌ ១១៣។

[150] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ២៨។

[151] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ២៩។

[152] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ៣០។

[153] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ៣០។

និងបន្ទាបឋានៈរបស់សហចៅក្រមស៊ើបអង្កេតជាតិឲ្យនៅក្រោមសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[154]។ លើសពីនេះទៀត សហមេធាវីការពារក្តីលើកឡើងថា ដោយហេតុថា អង្គបុរេជំនុំជម្រះមិនបានរកឃើញដោយសំឡេងភាគច្រើនលើសលុបថា សហចៅក្រមស៊ើបអង្កេតជាតិបានប្រព្រឹត្តកំហុស ឬរំលោភបំពានធ្ងន់ធ្ងរលើការប្រើប្រាស់ឆន្ទានុសិទ្ធិ ដែលរារាំងដល់ការអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដីកាលើកលែងចោទប្រកាន់ត្រូវមានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ[155]។

59. ជាចុងក្រោយ សហមេធាវីការពារក្តីគូសបញ្ជាក់ថា អង្គបុរេជំនុំជម្រះមានសិទ្ធិអំណាច និងភារកិច្ចបិទបញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿងទៅក្នុងបណ្ណសារ[156]។ ដោយយោងដល់សាលដីការបស់អង្គជម្រះតុលាការកំពូល[157] សហមេធាវីការពារក្តីលើកឡើងថា ការមិនឯកភាពក្នុងចំណោមចៅក្រម*អាច*បណ្តាលឲ្យបិទការចោទប្រកាន់[158]។ សហមេធាវីការពារក្តីបន្ថែមទៀតថា ក្នុងករណីមានឧបសគ្គយូរអង្វែងដែលរារាំងដល់កិច្ចដំណើរការនីតិវិធី ច្បាប់កម្ពុជាចែងអំពីលទ្ធភាពក្នុងការបង្គាប់ឲ្យផ្អាក ឬបញ្ឈប់ការចោទប្រកាន់[159]។ ដោយយល់ឃើញថា ការខ្វែងយោបល់គ្នាក្នុងរឿងក្តីនេះបង្កើតបានជាការរារាំងចៀសមិនរួចដល់កិច្ចដំណើរការនីតិវិធី សហមេធាវីការពារក្តីអះអាងថា ប្រសិនបើបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង អង្គបុរេជំនុំជម្រះខ្លួនឯងជាអ្នករំលោភលើនីតិវិធី ដោយចេតនា និងដោយស្មារតីទទួលខុសត្រូវ ដូចអ្វីដែលខ្លួនបានបន្ទោសដល់សហចៅក្រមស៊ើបអង្កេតដែរ[160]។

---

[154] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ៣០។

[155] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ៣១។

[156] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ៣២។

[157] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ៣២ យោងទៅ សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (E004/2/1/1/2) កថាខណ្ឌ ៥៣ ៦៧-៦៨ និង ៧១។

[158] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ៣២។

[159] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ៣៣។

[160] ចម្លើយតបរបស់សហមេធាវីការពារក្តី (ឯកសារ D271/3) កថាខណ្ឌ ៣៤។

01676419



## ៣. ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ

60. នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាជាតិជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[161] និងស្នើសុំឱ្យអង្គបុរេជំនុំជម្រះបិទបញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសាររបស់ អ.វ.ត.ក អនុលោមតាមវិធាន ៦៩(២)(ខ) នៃវិធានផ្ទៃក្នុង ដែលបង្គាប់ឱ្យរក្សាទុកសំណុំរឿងក្នុងបណ្ណសារ ក្រោយពីការចេញដីកាលើកលែងចោទប្រកាន់[162]។

61. ជាបឋម សហព្រះរាជអាជ្ញាជាតិកត់សម្គាល់ថា ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះបានសម្រេចថាសំណុំរឿង ០០៣ ត្រូវបញ្ជូនទៅតម្កល់ទុកក្នុងបណ្ណសាររបស់ អ.វ.ត.ក ហើយសហមេធាវីការពារក្តីបានដាក់សំណើសុំបិទបញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿងទៅក្នុងបណ្ណសារ[163]។ ក្រៅពីនេះទៀត ដើម្បីជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សហព្រះរាជអាជ្ញាជាតិអះអាងថា "សំណុំរឿង ០០៣ មានលក្ខណៈដូចគ្នានឹងសំណុំរឿង ០០៤/២" ដោយសារ ការពិតផ្នែកនៃសេចក្តីសម្រេចរួមនៃសេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ និងសេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ ដូចគ្នាបេះបិទ[164]។ លោកស្រីក៏បានគូសបញ្ជាក់ផងដែរថា៖ (១) អង្គបុរេជំនុំជម្រះមិនបានបង្គាប់ឱ្យក្រឡាបញ្ជីបញ្ជូនសំណុំរឿង[165] (២) សហចៅក្រមស៊ើបអង្កេតបានបង្គាប់ឱ្យបោះត្រា និងដាក់បញ្ចូលសំណុំរឿងក្នុងបណ្ណសារ តាមរយៈសេចក្តីសម្រេច ដែលជា "យុត្តិសាស្ត្រនៃសំណុំរឿង

---

[161] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D271/4) កថាខណ្ឌ ១៨។

[162] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D271/4) កថាខណ្ឌ ១៩ និង ២០។

[163] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D271/4) កថាខណ្ឌ ១២ និង ១៣ យោងដល់សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272)។

[164] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D271/4) កថាខណ្ឌ ១៤។

[165] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D271/4) កថាខណ្ឌ ១៥។

01676420



០០៤/២"[166] និង (៣) អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា "នឹងពុំមានការជំនុំជម្រះលើសំណុំរឿង [...] នៅពេលនេះ ឬនៅពេលអនាគតឡើយ[167]។

## គ. ការពិនិត្យលើភាពអាចទទួលយកបាន

### ១. តួនាទីរៀងៗខ្លួនរបស់ការិយាល័យចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ

62. ដើម្បីវាយតម្លៃភាពអាចទទួលយកបាននៃសំណើ អង្គបុរេជំនុំជម្រះរំលឹកដល់ភាគី អំពីតួនាទីរៀងៗខ្លួនរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត និងរបស់អង្គបុរេជំនុំជម្រះ។ អង្គបុរេជំនុំជម្រះសង្កេតឃើញតាំងពីដំបូងថា សហចៅក្រមស៊ើបអង្កេត[168] និងម្ចាស់បណ្ដឹង បាស្នើសុំអន្តរាគមន៍ពីអង្គបុរេជំនុំជម្រះ នៅក្រោមយុត្តាធិការបន្ថែម ខណៈដែលយុត្តាធិការគ្រឹះរបស់អង្គជំនុំជម្រះ ពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នា ត្រូវបានចៀសវាងដោយសហព្រះរាជអាជ្ញា[169] និងសហចៅក្រមស៊ើបអង្កេត[170]។

---

[166] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D271/4) កថាខណ្ឌ ១៦ យោងទៅ សំណុំរឿង ០០៤/២ ដីកាបង្គាប់ឲ្យបោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ឯកសារ D363/3។

[167] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D271/4) កថាខណ្ឌ ១៧។

[168] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង (ឯកសារ D270/7) កថាខណ្ឌ ៤៣។

[169] វិធាន ៧១.៣ នៃវិធានផ្ទៃក្នុង និងផ្ទុយពីនោះ គឺ ភាពទាល់ច្រកផ្នែកនីតិវិធី ដែលបានកត់សម្គាល់ជាពិសេសនៅក្នុង សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) កថាខណ្ឌ ៨៨។

[170] សូមមើលសំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១២៣ ("ប៉ុន្តែទោះជាបែបនេះក្ដី សហចៅក្រមស៊ើបអង្កេតនៅតែសម្រេចលាក់ការខ្វែងយោបល់គ្នា មិនឲ្យទទួលបានយន្តការដែលមានសម្រាប់ដោះស្រាយជម្លោះប្រកបដោយប្រសិទ្ធភាពបំផុតនៅក្រោមក្របខណ្ឌគតិយុត្ត អ.វ.ត.ក ដើម្បីធានានូវការចៀសផុតពីភាពទាល់ច្រកផ្នែកនីតិវិធីនោះទេ")។ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) កថាខណ្ឌ ១០៧។

63. នៅទីនេះ អង្គបុរេជំនុំជម្រះយោងទៅការវិភាគអចិន្ត្រៃយ៍របស់ខ្លួន អំពីភាពខុសច្បាប់នៃស្ថានភាព ដែលបណ្តាលមកពីការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា[171] ហើយផ្តោតទៅលើផលប៉ះពាល់នៃស្ថានភាពនេះ នៅដំណាក់កាលបច្ចុប្បន្ននៃការស៊ើបអង្កេត។

64. តាំងតែពីដើមដំបូង អង្គបុរេជំនុំជម្រះបានរំលឹកថា "គឺជាការទទួលខុសត្រូវរួមគ្នារបស់សហចៅក្រម [ស៊ើបអង្កេត] ពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស ដោយអនុវត្តតាមនីតិវិធីជាធរមាន"[172]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតទទួលបន្ទុកបើកកិច្ចស៊ើបសួរនៅ អ.វ.ត.ក ហើយរួមគ្នាទទួលខុសត្រូវ ដើម្បីដំណើរការឱ្យបានល្អ[173]។ អាស្រ័យហេតុនេះ ថ្វីត្បិតតែអង្គបុរេជំនុំជម្រះដើរតួនាទីក្នុងនាមជាស្ថាប័នមួយស្រដៀងគ្នានឹងសភាស៊ើបសួរកម្ពុជា ក៏ប៉ុន្តែ អង្គបុរេជំនុំជម្រះធ្វើអន្តរាគមន៍ ក្នុងនាមជាស្ថាប័នស៊ើបសួរថ្នាក់ទីពីរ ដើម្បីពិនិត្យមើលនិយតភាពនៃនីតិវិធី ស្របតាមវិធានច្បាប់ជាធរមានចំពោះមុខខ្លួន[174]។

65. អង្គបុរេជំនុំជម្រះរំឭកឡើងវិញនូវសេចក្តីសង្កេតរបស់ខ្លួនដូចតទៅ ៖

> [សហចៅក្រមស៊ើបអង្កេត]បានដឹងថា ក្នុងការបដិសេធមិនបញ្ជូនករណីខ្វែងយោបល់របស់ពួកគាត់ទៅអង្គបុរេជំនុំជម្រះ បញ្ហាទាំងអស់ដែលពួកគាត់ជំទាស់ រួមទាំងបញ្ហាគន្លឹះដែលថាតើ មាស មុត ស្ថិតឬមិនស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក នឹងត្រូវដោះស្រាយតែក្នុងក្របខណ្ឌនៃកិច្ចដំណើរការបណ្តឹងឧទ្ធរណ៍ នៅចំពោះមុខអង្គជំនុំជម្រះនេះប៉ុណ្ណោះ

---

[171] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១២១ និង ១២២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) កថាខណ្ឌ ១០៤ និង ១០៥។

[172] ច្បាប់បង្កើត អ.វ.ត.ក មាត្រា ២៣ (ថ្មី)។

[173] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) កថាខណ្ឌ ៧៩។

[174] សូមមើលសំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៣៨ ដល់ ៤៣។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ១២៥។

01676422



តែមិនមែនតាមរយៈយន្តការនីតិវិធី ដែលបានចែងដាក់លាក់នៅក្នុងក្របខណ្ឌគតិយុត្តិនៃ អ.វ.ត.ក សម្រាប់ដោះស្រាយជាស្ថាពរនូវករណីខ្វែងយោបល់គ្នារវាងពួកគាត់នោះទេ។ សហចៅក្រមស៊ើបអង្កេតបានដឹងពីការលំបាកនានាបណ្តាលមកពីសកម្មភាពរបស់ពួកគាត់ មិនត្រឹមតែនៅក្នុងដំណាក់កាលបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះទេ តែវាហួសពីដំណាក់កាលបណ្តឹងឧទ្ធរណ៍មុនការជំនុំជម្រះ នៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ទៅទៀត[175]។

66. អង្គបុរេជំនុំជម្រះកត់សំគាល់ថា សហព្រះរាជអាជ្ញាអន្តរជាតិអះអាងនៅពេលនេះថា អង្គជំនុំជម្រះត្រូវចេញសេចក្តីសម្រេចបិទបញ្ចប់ការស៊ើបអង្កេតតាមផ្លូវតុលាការ ស្របតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក[176]។ លើសពីនោះ សហព្រះរាជអាជ្ញាអន្តរជាតិវាយតម្លៃថា អង្គបុរេជំនុំជម្រះទំនងជាខកខានមិនបានបំពេញភារកិច្ចតុលាការ និងបណ្តាលឱ្យមានភាពអយុត្តិធម៌ជាក់ស្តែង[177]។ សហមេធាវីការពារក្តីក៏យល់ស្របតាមការពិចារណានោះ[178] ហើយបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះកុំបោះបង់ការទទួលខុសត្រូវរបស់ខ្លួន[179]។ សហចៅក្រមស៊ើបអង្កេតខ្លួនឯង ក៏បានធ្វើការទិតៀនទៅលើអ្វីដែលគេអះអាងថាជា "តម្រូវការ" ឲ្យមានសេចក្តីសម្រេចរួមរបស់អង្គជំនុំជម្រះ[180]។

---

[175] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) កថាខណ្ឌ ១០៧។ សូមមើលផងដែរ ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (ឯកសារ D262.2) កថាខណ្ឌ ១៥ និង ១៦។

[176] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ១២ ដល់១៧។

[177] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D271/1) កថាខណ្ឌ ១២ ដល់ ១៧។

[178] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៣៦, ៤៧ និង ៦០ ដល់ ៦៩។

[179] សំណើរបស់សហមេធាវីការពារក្តី (ឯកសារ D272) កថាខណ្ឌ ៤៧។

[180] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង (ឯកសារ D270/7) កថាខណ្ឌ ៣។

67. អង្គបុរេជំនុំជម្រះមិនយល់ស្របតាមអំណះអំណាងបែបនោះទេ ហើយរំឭកថា ជាគោលការណ៍ សហចៅក្រមស៊ើបអង្កេតមួយរូបអាចបំពេញកិច្ចតែម្នាក់ឯងដោយត្រឹមត្រូវ តាំងពីដំបូងមកម្ល៉េះ[181]។ ដូចច្នេះ អង្គបុរេជំនុំជម្រះមានការសោកស្តាយ ដែលសហចៅក្រមស៊ើបអង្កេតមិនបានប្រើប្រាស់អំណាចយុត្តាធិការបុគ្គលរបស់ខ្លួន ដោយចេញដីកាដំណោះស្រាយ*មួយ* ឬដោយបញ្ជូនរឿងទៅអង្គបុរេជំនុំជម្រះ ដើម្បីដោះស្រាយការខ្វែងគំនិតគ្នារវាងពួកគេ។ ម្យ៉ាងវិញទៀត ទោះបីចៅក្រមស៊ើបអង្កេតទទួលបានអត្ថប្រយោជន៍ពីអំណាចឯកតោភាគីនេះ ដើម្បីបិទបញ្ចប់ការស៊ើបអង្កេតតាមផ្លូវតុលាការដោយខ្លួនឯង ស្របតាមច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក ក៏ដោយ ក៏អង្គបុរេជំនុំជម្រះមិនមានសិទ្ធិអំណាចបែបនេះទេ។

68. ជាក់ស្តែង អង្គបុរេជំនុំជម្រះរំឭកថា អង្គបុរេជំនុំជម្រះជាក្រុមប្រឹក្សាជំនុំជម្រះរួម ដែលរាល់សេចក្តីសម្រេចទាំងឡាយ ត្រូវបានអនុវត្តតាមច្បាប់ដែលមានចែងក្នុងកិច្ចព្រមព្រៀង ច្បាប់បង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង។ គេអាចនិយាយម្យ៉ាងទៀតថា ខុសពីច្បាប់ជាធរមាននៅក្នុងការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះមិនមានកាតព្វកិច្ចទាល់តែសោះក្នុងការចេញសេចក្តីសម្រេចជាឯកច្ឆ័ន្ទ។ ផ្ទុយទៅវិញ វាជាកាតព្វកិច្ចរបស់ចៅក្រមម្នាក់ៗដែលត្រូវសម្រេចតែម្នាក់ឯងដោយមនសិការ និងត្រូវផ្តល់សំអាងហេតុនៃមតិផ្ទាល់ខ្លួន[182]។ គ្មានអត្ថបទច្បាប់ណាដែលតម្រូវឱ្យអង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទឡើយ ហើយវិធាន ៧៧.១៤ នៃវិធានផ្ទៃក្នុងដើរផ្ទុយពីអំណះអំណាងដែលបង្ហាញដោយម្ចាស់បណ្តឹង៖ ចៅក្រមនៃអង្គបុរេជំនុំជម្រះមានកាតព្វ

---

[181] សូមមើល សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១០៥។ សំណុំរឿង ០០៤/១ (អបជ ២០) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើញត្តិសុំពិចារណាឡើងវិញ និងលុបចោលដីកាកោះ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤, ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D236/1/1/8 កថាខណ្ឌ ៣០។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ០៩) សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រី ឱ្យមកបង្ហាញខ្លួនជាលើកដំបូង ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤ ឯកសារ A122/6.1/3 កថាខណ្ឌ ១៤។

[182] សូមមើលវិធាន ៧១.៤.ឃ និង ៧២.៤.ង (ទាក់ទងនឹងការខ្វែងគំនិតគ្នា)។ វិធាន ៧៧.១៤ (ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ និងបណ្តឹងសុំមោឃភាព)។

កិច្ចចេញសេចក្ដីសម្រេច និងផ្ដល់សំអាងហេតុនៃមតិដាច់ដោយឡែករបស់ពួកគេរៀងខ្លួន។ ដូច្នេះ តាមផ្លូវច្បាប់ វាមិនត្រឹមត្រូវទេក្នុងការតម្រូវឱ្យមានការសម្រេចជាឯកច្ឆ័ន្ទពីក្រុមប្រឹក្សាជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋានគ្រឹះនៃកាតព្វកិច្ចគតិយុត្តិស្រមើស្រមៃមួយ ខណៈដែលកាតព្វកិច្ចនោះត្រូវធ្លាក់ទៅលើសហចៅក្រមស៊ើបអង្កេតយ៉ាងពិតប្រាកដ។ ការខកខានមិនបំពេញករណីយកិច្ចរបស់ពួកគេ បានបង្កគ្រោះថ្នាក់ដល់ដំណើរការរបស់ អ.វ.ត.ក[183] ជាពិសេស ដោយមិនផ្ដល់លទ្ធភាពឱ្យអង្គបុរេជំនុំជម្រះដោះស្រាយការខ្វែងគំនិតគ្នា ស្របតាមវិធាន ៧២ ហើយក្នុងន័យនេះ គឺជាការរារាំងដល់សច្ចាធារណ៍ស្របច្បាប់ដែលជាប់ពាក់ព័ន្ធ រួមទាំងវិធាននៃការបកស្រាយសេចក្ដីសម្រេច ឬសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ[184]។

---

[183] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១២៣។ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ១០៨។

[184] សហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់យ៉ាងទូលំទូលាយថា ពួកគាត់សម្រេចមិនបញ្ជូនករណីខ្វែងយោបល់របស់ខ្លួនទៅអង្គបុរេជំនុំជម្រះ ដោយសារពួកគាត់ដឹងអំពី "សេចក្ដីសន្និដ្ឋាន*បែបទុំជោរ*" នៃការបញ្ជូននេះ ដោយសារតែមានការខ្វែងយោបល់គ្នាជាយូរមកហើយទៅលើយុត្តាធិការបុគ្គលនៅក្នុងអង្គជំនុំជម្រះ។ ពួកគាត់យល់ឃើញថា ចៅក្រមនៃអង្គជំនុំជម្រះនឹងមិន "ផ្លាស់ប្ដូរចិត្ត*បែបអច្ឆរិយៈ*" នោះឡើយ ទោះបីមានការបញ្ជូនដោយត្រឹមត្រូវយ៉ាងណាក៏ដោយ (*សូមមើល* សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង" (ឯកសារ D270/7) កថាខណ្ឌ ១៥ (គូសបញ្ជាក់បន្ថែម))។ ដោយសារមានការយល់ដឹងបែបនេះ យើងអាចយល់បានដោយហួសពីវិមតិសង្ស័យថា សហចៅក្រមស៊ើបអង្កេតក៏បានដឹងផងដែរពីលទ្ធផលទុំជោរនៃការបញ្ជូនសំណុំរឿង ជាលទ្ធផលដែលជំរុញឱ្យមានគោលជំហរជាក់ស្ដែងដោយចៀសមិនរួច។ ការពិត វិធាននៃមតិភាគច្រើនលើសលប់ និងដំណើរការជាធម្មតានៃគោលជំហរជាក់ស្ដែង ដែលអាចដំណើរការទៅបានដោយគ្មានឧបសគ្គនៅក្នុងដីកាដំណោះស្រាយដែលមានតែមួយនោះ ត្រូវទទួលរងការប៉ះពាល់ធ្ងន់ធ្ងរដោយការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា។ ករណីខ្វែងយោបល់ដោយខុសច្បាប់របស់សហចៅក្រមស៊ើបអង្កេតបានបង្កើតជា*ការសម្រេចមិនអាចកែប្រែបាន (fait accompli)* និងជាបុព្វហេតុដែលនាំឱ្យមាន "ភាពមិនប្រាកដប្រជាផ្នែកច្បាប់" នាពេលបច្ចុប្បន្ននៅ អ.វ.ត.ក។

*សេចក្ដីសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវីការពារក្ដីមាស មុត ពាក់ព័ន្ធនឹង*
*កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០៣*

## ២. អង្គបុរេជំនុំជម្រះបានបំពេញភារកិច្ចរបស់ខ្លួនក្នុងសំណុំរឿង ០០៣

69. ក្នុងតួនាទីជាសភាស៊ើបសួរ ស្របតាមមាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងមាត្រា ២៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា អង្គបុរេជំនុំជម្រះជាយុត្តាធិការចុងក្រោយលើការស៊ើបអង្កេត[185] រួមទាំងរាល់សំណើទាំងអស់ពាក់ព័ន្ធនឹងដំណាក់កាលមុនការជំនុំជម្រះ បន្ទាប់ពីការិយាល័យសហចៅក្រមស៊ើបអង្កេតលែងមានសិទ្ធិទទួលសំណុំរឿង[186]។

70. ម៉្យាងវិញទៀត សំណើដែលបានដាក់ជូនសភាស៊ើបសួរ ស្ថិតនៅក្រោមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ដែលចែងថា "នៅគ្រប់ពេលវេលានៃការស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍"។

71. ជាបឋម អង្គបុរេជំនុំជម្រះកត់សំគាល់ថា អត្ថបទនេះមិនអនុញ្ញាតឱ្យដាក់សំណើឡើយ ខណៈដែលការស៊ើបអង្កេតបានបញ្ចប់នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ ដោយមានការចេញសេចក្តីពិចារណានៅក្នុងរឿង ០០៣។

---

[185] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៤០ និង ៤១។ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ២២។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ៤១។ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច នាថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៧ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ C5/45 កថាខណ្ឌ ៧។

[186] ជាឧទាហរណ៍ សូមមើលសំណុំរឿង ០០៤/២ (អបជ ៥៩) សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការកោសលុប និងការចាត់វិធានការបណ្តោះអាសន្ន ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ D360/3 កថាខណ្ឌ ៥ និង ១៣។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ១៣២។

72. អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា សំណើរបស់ម្ចាស់បណ្ដឹងបានបំពេញរួចហើយ តាមលក្ខខណ្ឌនៃសេចក្ដីពិចារណានៅក្នុងសំណុំរឿង ០០៣។ ជាក់ស្ដែង ផ្នែកសម្រេចសេចក្ដីរួមនៃសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ត្រូវបានជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត ដើម្បីប្រគល់ភារកិច្ចចាត់ការសំណុំរឿង ដោយអនុលោមតាមវិធាន ៧៧(១៣) និង ៧៧(១៤) នៃវិធានផ្ទៃក្នុង។ តាមរយៈការជូនដំណឹងអំពីសេចក្ដីពិចារណារបស់ខ្លួន អង្គបុរេជំនុំជម្រះបានបំពេញកាតព្វកិច្ចពេញលេញរបស់ខ្លួនរួចហើយ[187]។ អំណឹះតទៅ សហចៅក្រមស៊ើបអង្កេតគួរតែអនុវត្តតាមភ្លាមៗជាបន្ទាន់។ តាមទស្សនៈនេះ ការរៀបចំសមាសភាពនៃការិយាល័យសហចៅក្រមស៊ើបអង្កេតឡើងវិញ នឹងធ្វើឱ្យស្ថាប័ននេះមានសមត្ថភាពបំពេញមុខងាររបស់ខ្លួន គឺមិនដូចការបន្តអនុវត្តលើសេចក្ដីពិចារណាក្នុងសំណុំរឿង ០០៤/២ នោះទេ[188]។

73. ជាចុងក្រោយ និងជាសារវ័ន្ត អង្គបុរេជំនុំជម្រះបានសម្រេចពីរលើករួចមកហើយ រួមទាំងពេលនេះផងនូវភាពមិនស្របច្បាប់នៃស្ថានភាពដែលបង្កឡើងដោយសហចៅក្រមស៊ើបអង្កេតទាំងពីររូប ដែលមិនព្រមដាក់ពាក្យបណ្ដឹងតាមផ្លូវច្បាប់ ដើម្បីដោះស្រាយការខ្វែងគំនិតគ្នា និងដើម្បីចេញដីកាដំណោះស្រាយផ្ទុយគ្នា។

74. អង្គបុរេជំនុំជម្រះគូសបញ្ជាក់ពីភាពស្មុគ្រស្មាញ ដែលសហចៅក្រមស៊ើបអង្កេតកំពុងជួបប្រទះ ដើម្បីដោះស្រាយផលវិបាកនៃការអនុវត្តមិនត្រឹមត្រូវរបស់ពួកគេ និងការរំលោភបំពានដោយចេតនាលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក។ ជាក់ស្ដែង គ្មាននរណាប្រសើរជាងសហចៅក្រមស៊ើបអង្កេតខ្លួនឯងទេ ដែលបានបង្ហាញពីការប៉ុនប៉ងគេចវេសពីផលវិបាកនៃកំហុសរបស់ខ្លួន ដោយមិនបោះបង់

---

[187] សូមមើលសេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) ផ្នែកសម្រេចសេចក្ដី ទំព័រ ៤៦។

[188] សូមមើល សេចក្ដីថ្លែងការណ៍របស់ អ.វ.ត.ក "International Co-Investigating Judge Reinstated" ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ Statement: International Co-Investigating Judge Reinstated | Drupal (eccc.gov.kh) (ពិគ្រោះចុងក្រោយ៖ នៅថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០២១) នៅក្នុងនោះ មានការអះអាងថាការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវបានប្ដូរសមាសភាពថ្មីនៅថ្ងៃទី ២២ ខែមេសា ឆ្នាំ២០២០។

មិនសមស្រប ដោយហេតុថាៈ ១) ថ្វីត្បិតតែសហចៅក្រមទាំងពីររូបមានកាតព្វកិច្ចតាមផ្លូវច្បាប់ អនុលោមតាមវិធាន ៧៧(១៣) និង (១៤) នៃវិធានផ្ទៃក្នុងក៏ដោយ តែសហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីសម្រេចមួយ[189] ទៅលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលសុំ*បញ្ជូន*សំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង[190] ២) ការសម្រេចនោះធ្វើឡើងដោយហេតុផលអសមត្ថភាព ក្នុងការសម្រេចជោគវាសនាសំណុំរឿង ០០៣ ទោះបីជាសហចៅក្រមស៊ើបអង្កេតសម្រេចទុកជាមុនលើ "ជោគវាសនានៃសំណុំរឿងនេះ" ក្តី ប្រសិនបើជាថៃ្ងណាមួយសំណុំរឿងនោះត្រឡប់មកនៅចំពោះមុខ ពួកគេឡើងវិញក៏ដោយ[191] និង ៣) សហចៅក្រមស៊ើបអង្កេតអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិឱ្យប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចចិត្តរបស់ពួកគេផ្ទាល់[192]។ អង្គបុរេជំនុំជម្រះយល់ ឃើញថា នេះជា "ស្ថានភាពទុំជោរ" ដែលសហចៅក្រមស៊ើបអង្កេតបានបង្កើតឡើង ក្នុងការបដិសេធមិនអនុវត្តតាមច្បាប់ឱ្យបានតឹងរ៉ឹង រួមទាំងវិធាន ៧២ នៃវិធានផ្ទៃក្នុង។

75. ក្នុងន័យនេះ អង្គបុរេជំនុំជម្រះបានចោទសួរបន្ថែមអំពីហេតុផលរបស់ចៅក្រមស៊ើបអង្កេតម្នាក់ ដែលបន្ទាប់ពីបញ្ជាឱ្យបញ្ជូនជនត្រូវចោទទៅជំនុំជម្រះពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មផ្សេងៗទៀត ក្រោមច្បាប់កម្ពុជា ហើយបន្ទាប់ពីស៊ើបអង្កេតរយៈពេលដប់ឆ្នាំ ស្រាប់តែប្រកាសសម្រេចក្រោមមូលដ្ឋានស្របច្បាប់ស្រមើស្រមៃ[193] ថាគ្មាន

---

[189] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង (ឯកសារ D270/7) ទំព័រ ២៩។

[190] សំណុំរឿង ០០៣ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យសហចៅក្រមស៊ើបអង្កេតបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ (ឯកសារ D270) (គូសបញ្ជាក់បន្ថែម)។

[191] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង (ឯកសារ D270/7) កថាខណ្ឌ ៤០។

[192] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង (ឯកសារ D270/7) កថាខណ្ឌ ៤៣។

[193] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង (ឯកសារ D270/7) កថាខណ្ឌ ៣៥ ដោយប្រៀបធៀបជាមួយនឹងវិធាន ៦៧(៣) នៃវិធាននីតិវិធី។

01676428



សមត្ថភាពក្នុងការប្ដឹងក្រុមប្រឹក្សាជំនុំជម្រះ[194] ហើយអាចត្រៀមខ្លួនដាក់ដំណើរការនីតិវិធីចូលក្នុងបណ្ណសារទៅវិញ[195]។

76. ដោយបានបំពេញមុខងារសព្វគ្រប់ដែលបានប្រគល់ជូន ស្របតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក និង ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាផង អង្គបុរេជំនុំជម្រះមានបំណងប្រកាន់ខ្ជាប់នូវសេចក្តីពិចារណារបស់ខ្លួន។ អង្គបុរេជំនុំជម្រះបដិសេធដាច់អហង្ការ ថាមិនបានជាប់ទាក់ទងនឹងការប្រព្រឹត្តិរបស់សហចៅក្រមស៊ើបអង្កេតកន្លងទៅ ឬសំណើដែលបានទទួលយករួចមកហើយ ក៏ដូចជាការអនុវត្តមិនត្រឹមត្រូវដែលនាំទៅរកភាពបរាជ័យដែលអ្នកបង្កទំនងជាមិនអាចជម្នះបាន។

77. នៅចុងបញ្ចប់ អង្គបុរេជំនុំជម្រះរំឭកពីយុត្តិសាស្ត្រអចិន្ត្រៃយ៍របស់ខ្លួន ដែលអាចបដិសេធបណ្តឹងឧទ្ធរណ៍ ឬសំណើមិនចាំបាច់ និងដែលអាចបង្កវិវាទគ្មានទីបញ្ចប់[196]។ ដូចជាករណីសំណើសុំលើកឡើងពីបញ្ហាដែលមានសារៈសំខាន់ប្រហាក់ប្រហែលគ្នា (តាមអង្គហេតុ និងអង្គច្បាប់) ទៅនឹងសំណួរដែលអង្គជំនុំជម្រះបានពិចារណារួចហើយ ទាក់ទងនឹងភាគីតែមួយ ដែលអង្គបុរេជំនុំជម្រះមិនអាចឈានទៅទទួលបានសំឡេងភាគច្រើន ៤ សំឡេង ដើម្បីចេញសេចក្តីសម្រេច និងដែលរំពឹងថាចៅក្រម

---

[194] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង (ឯកសារ D270/7) កថាខណ្ឌ ៣៥។

[195] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង (ឯកសារ D270/7) កថាខណ្ឌ ៣៧។

[196] សំណុំរឿង ០០៤/២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D190/1/2 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួររបស់ តា អាន (D190/1/2)") កថាខណ្ឌ ២០។ សំណុំរឿង ០០៤/២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤ ឯកសារ D185/1/1/2 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធពាក្យសុំមោឃភាពរបស់ តា អាន (D185/1/1/2)") កថាខណ្ឌ ១៤ ដល់ ១៥។

នឹងរក្សាទស្សនៈដូចគ្នាលើបញ្ហានោះ[197]។ ក៏ប៉ុន្តែ អង្គបុរេជំនុំជម្រះបានសម្រេចរួចហើយលើចំណុចនានាដែលលើកឡើងក្នុងសំណើ នៅក្នុងផ្នែកអង្គសេចក្តីដែលសម្រេចលើសេចក្តីពិចារណាក្នុងសំណុំរឿង ០០៣[198]។

78. ដូច្នេះ អង្គបុរេជំនុំជម្រះសូមប្រកាសមិនទទួលយកសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងសំណើរបស់សហមេធាវីការពារក្តី។

---

[197] សំណុំរឿង ០០៤/២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួររបស់ តា អាន (D190/1/2) កថាខណ្ឌ ២០។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធពាក្យសុំមោឃភាពរបស់ តា អាន (D185/1/1/2) កថាខណ្ឌ ១៤ ដល់ ១៥។

[198] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) ផ្នែកសម្រេចសេចក្តី ទំព័រ ៤៦។

## V. ផ្នែកសម្រេចសេចក្ដី

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះ ជាឯកច្ឆន្ទ ÷**

- **ប្រកាសមិនទទួលយកសំណើ**ទាំងនេះឡើយ។

ដោយអនុលោមតាម វិធាន ៧៧ នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចនេះបិទផ្លូវតវ៉ា។

ដោយអនុលោមតាម វិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចនេះ ត្រូវជូនដំណឹងទៅសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងទៅភាគីផ្សេងទៀត តាមរយៈក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ផុល** **Kang Jin BAIK** **ហួត វុទ្ធី**